ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# របាយការណ៍

## ការសិក្សាស្រាវជ្រាវស្តីពីអាពាហ៍ពិពាហ៍នៅវ័យក្មេង

## អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង

មិថុនា ២០២៤

គាំទ្រដោយ ៖ PLAN INTERNATIONAL

# មាតិកា


អារម្ភកថា.......................................................................................................2
សេចក្តីសង្ខេប ...............................................................................................3
បញ្ជីអក្សរកាត់...............................................................................................9
បញ្ជីតារាង...................................................................................................10
I. សារតារនៃការសិក្សា....................................................................................11
II. គោលបំណងនៃការសិក្សា ............................................................................12
III. វិធីសាស្រ្តស្រាវជ្រាវ.....................................................................................13
៣.១ តំបន់នៃការសិក្សា......................................................................................13
៣.២ សំណាកនិងទំហំសំណាក ............................................................................13
៣.៣ វិធីសាស្រ្តជ្រើសរើសសំណាក .......................................................................13
៣.៤ វិធីសាស្រ្តប្រមូលទិន្នន័យ ...........................................................................14
៣.៥ ការគ្រប់គ្រង និងវិភាគទិន្នន័យ.....................................................................14
៣.៦ ក្រមសីលធម៌...........................................................................................15
៣.៧ វិសាលភាព និងដែនកំណត់នៃការសិក្សា.......................................................16
IV. របកគំហើញ និងការវិភាគ .........................................................................16
៤.១ របកគំហើញពីការត្រួតពិនិត្យលើទិន្នន័យដែលមានស្រាប់.................................16
៤.១.១ បញ្ញត្តិគោល និង និយមន័យ ......................................................................16
៤.១.២ លិខិតបទដ្ឋានគតិយុត្តិជាតិនិងការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង........................................................18
៤.១.៣ ទិដ្ឋភាពទូទៅនៃការរៀបអាពាហ៍ពិពាហ៍ក្នុងសង្គមកម្ពុជា .................................22
៤.១.៤ របាយការណ៍ទាក់ទងនឹង CEFMU នៅប្រទេសកម្ពុជា.......................................23
៤.១.៥ របាយការណ៍ទាក់ទងនឹងអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងនៅប្រទេសកម្ពុជា..................................................23
៤.១.៦ ការធ្វើអន្តរាគមន៍របស់រាជរដ្ឋាភិបាលកម្ពុជាលើបញ្ហា CEFMU នាពេលកន្លងមក..................25
៤.២ របកគំហើញដែលទទួលបានពីការស្ទង់មតិ និងការសម្ភាសន៍...............................26
៤.២.១ បុគ្គលិកលក្ខណៈសង្គម-ប្រជាសាស្រ្តរបស់អ្នកឆ្លើយតប.....................................26
៤.២.២ ផ្នត់គំនិត និងចំណេះដឹងអំពី CEFMU..........................................................30
៤.២.៣ ប្រេវ៉ាឡង់នៃ CEFMU..............................................................................37
៤.២.៤ ប្រេវ៉ាឡង់នៃ CEFMU នៅតាមខេត្តគោលដៅ ...................................................39
៤.២.៥ ឫសគល់/កត្តាពាក់ព័ន្ធនៃ CEFMU ...............................................................41
៤.២.៦ ផលប៉ះពាល់នៃ CEFMU ...........................................................................50
៤.២.៧ បទពិសោធន៍របស់អ្នកឆ្លើយតបក្នុងកិច្ចអន្តរាគមន៍ដោះស្រាយ CEFMU.......................59
V. សេចក្តីសន្និដ្ឋាន និងអនុសាសន៍....................................................................60
៥.១ សេចក្តីសន្និដ្ឋាន.......................................................................................60
៥.២ អនុសាសន៍ ............................................................................................63

# អារម្ភកថា

របាយការណ៍សិក្សាស្រាវជ្រាវ ស្តីពីអាពាហ៍ពិពាហ៍វ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង បានរៀបចំឡើងដោយក្រសួងកិច្ចការនារី សហការជាមួយអង្គការភ្លែនអន្តរជាតិក្នុងគោលបំណងសិក្សាស្វែងរកមូលហេតុ និន្នាការ ឥទ្ធិពល និងផលប៉ះពាល់នៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង។ លទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញអំពីការរំលោភបំពានសិទ្ធិកុមារ ក្មេងស្រី និងស្ត្រី ជាពិសេសការបង្កគ្រោះថ្នាក់ដល់សុខភាពបន្តពូជ និងរារាំងក្មេងស្រី និងស្ត្រីក្នុងការទទួលបានឱកាសអប់រំ ការចូលរួមក្នុងសង្គម សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដែលជាកត្តានាំឱ្យក្មេងស្រីជួបប្រទះ អំពើហិង្សា ហើយជះឥទ្ធិពលដល់ការអភិវឌ្ឍរបស់មនុស្ស និងសង្គមជាតិផងដែរ។

របកគំហើញនៃការសិក្សាស្រាវជ្រាវបង្ហាញថា អត្រានៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងបានថយចុះ នៅតំបន់ភូមិសាស្ត្រមួយចំនួន។ អត្រាប្រេវ៉ាឡង់នៃការរៀបការមុនអាយុ ១៨ឆ្នាំ នៅតែខ្ពស់នៅឡើយ ដោយសារតែសេដ្ឋកិច្ចគ្រួសារ កង្វះចំណេះដឹង វិសមភាពយេនឌ័រ បទដ្ឋានសង្គមនិងវប្បធម៌ ឥទ្ធិពលអ៊ីនធឺណែតនិងបណ្តាញសង្គម និងការអនុវត្តច្បាប់នៅមិនទាន់ពេញលេញ។ ការកើតឡើងនូវផលប៉ះពាល់ពីការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង បង្កជាផលវិបាកដល់ក្មេងស្រីដូចជាការមានផ្ទៃពោះនៅវ័យក្មេងប៉ះពាល់សុខភាពបន្តពូជ សុខភាពផ្លូវចិត្ត ការរំលូតកូនដោយអសុវត្ថិភាព អំពើហិង្សាក្នុងគ្រួសារ និងបាត់បង់សិទ្ធិសេរីភាពក្នុងការចូលរួមការងារសង្គម និងការធ្វើការសម្រេចចិត្ត ។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០២១-២០២២ ក៏បានបង្ហាញថា មានការថយចុះនូវអត្រានៃអាពាហ៍ពិពាហ៍វ័យក្មេង ក៏ប៉ុន្តែនៅតែជាបញ្ហាសម្រាប់ប្រទេសកម្ពុជាដែលត្រូវដោះស្រាយ។

របាយការណ៍នៃការសិក្សាស្រាវជ្រាវនេះ នឹងក្លាយជាមូលដ្ឋានក្នុងការរៀបចំផែនការសកម្មភាពជាតច្បាស់លាស់មួយដើម្បីពន្លឿនការដោះស្រាយបញ្ហានៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងក្នុងប្រទេសកម្ពុជា។

ក្រសួងកិច្ចការនារី សូមអរគុណដល់ក្រុមការងារក្រសួងកិច្ចការនារី ទីប្រឹក្សាឯករាជ្យជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងការពិនិត្យ និងកែសម្រួលរបាយការណ៍នៃការសិក្សាស្រាវជ្រាវស្តីពី អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យព្រមទាំងសូមអរគុណចំពោះថ្នាក់ដឹកនាំទទួលបន្ទុកដែលបានផ្តល់ការគាំទ្រ និងជំរុញដំណើរការនៃរៀបចំការក្មេង សិក្សាស្រាវជ្រាវនេះឱ្យទទួលបានជោគជ័យ ។

ក្រសួងកិច្ចការនារី សូមថ្លែងអំណរគុណចំពោះអង្គការភ្លែនអន្តរជាតិ ដែលបានគាំទ្រផ្នែកហិរញ្ញវត្ថុបច្ចេកទេសសម្រាប់ដំណើរការរៀបចំការសិក្សាស្រាវជ្រាវនិងបោះពុម្ពឯកសារនេះ។ Hư

ថ្ងៃពុធ ១៣កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤
**រដ្ឋមន្ត្រី**
**ក្រសួងកិច្ចការនារី**

**ឃឹ សាមិត្ត**

# សេចក្តីសង្ខេប


សេចក្តីសង្ខេបបង្ហាញនូវលទ្ធផលនៃការស្រាវជ្រាវយ៉ាងទូលំទូលាយពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង។ ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងក្រោមការឧបត្ថម្ភគាំទ្ររបស់ក្រសួងកិច្ចការនារី សហការជាមួយនឹងអង្គការផ្លែនអន្តរជាតិកម្ពុជា។

**គោលបំណងនៃការស្រាវជ្រាវ៖** គោលបំណងចម្បងនៃការសិក្សានេះមាន៖ 1) ពិនិត្យអំពីអត្រាប្រេវ៉ាឡង់ មូលហេតុ កត្តាជំរុញ និន្នាការនិងផលប៉ះពាល់នៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់ជាប្តីប្រពន្ធនៅវ័យក្មេង ចំពោះក្មេងដែលមានអាយុតិចជាង 15 ឆ្នាំ និងអាយុក្រោម 18 ឆ្នាំ; 2) ពិនិត្យឡើងវិញនូវច្បាប់ និងគោលនយោបាយដែលមានស្រាប់ដែលទាក់ទងនឹងអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់ជាប្តីប្រពន្ធនៅវ័យក្មេង និងការកំណត់អត្តសញ្ញាណ ចំណុចខ្វះខាតដែលទាក់ទងនឹងផ្នែកច្បាប់ គោលនយោបាយ និងការអនុវត្តកន្លងមក; 3) ពិភាក្សាលើចំណុចសំខាន់ៗនៃសកម្មភាពជាក់ស្តែង និងការកែលម្អគោលនយោបាយ/យុទ្ធសាស្ត្រដែលអាចធ្វើទៅបាន និង/ឬការរៀបចំផែនការសកម្មភាពជាតិដើម្បីដោះស្រាយបញ្ហាការរៀបការនៅវ័យក្មេង និងការមានគភ៌ក្នុងវ័យជំទង់ និង; 4) ផ្តល់ជាអនុសាសន៍ដែលអាចអនុវត្តបានក្នុងគោលបំណងពន្លឿនកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយជាអតិបរិមានូវអាពាហ៍ពិពាហ៍វ័យក្មេង និងការមានផ្ទៃពោះក្នុងវ័យជំទង់។

**វិធីសាស្ត្រស្រាវជ្រាវ៖** ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ការសិក្សានេះត្រូវបានធ្វើឡើងដោយការរួមបញ្ចូលគ្នានូវវិធីសាស្ត្របែបគុណភាព និងបែបបរិមាណ។ ការសិក្សាលើទិន្នន័យដែលមានស្រាប់ត្រូវបានធ្វើឡើងដើម្បីវិភាគទៅលើឯកសារដែលមានស្រាប់ រួមមានរបាយការណ៍ គោលនយោបាយ និងខ្លឹមសារផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំនិងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង។ គោលបំណងនៃការសិក្សានេះ ដើម្បីវាយតម្លៃទៅលើព័ត៌មាន និងរបាយការណ៍ដែលមានស្រាប់ រកឃើញភាពខ្វះចន្លោះអំពីទិន្នន័យនិងការស្រាវជ្រាវណាមួយ ហើយធ្វើឱ្យមានសុពលភាពចំពោះវិធីសាស្ត្រសិក្សា និងឧបករណ៍ប្រមូលទិន្នន័យ។ ការប្រមូលទិន្នន័យបែបបរិមាណ ធ្វើឡើងតាមរយៈការស្ទង់មតិជាមួយនឹងស្ត្រីដែលមានអាយុចាប់ពី២០ឆ្នាំដល់២៤ឆ្នាំ សរុបចំនួន១៣៥០ នាក់ដែលបង្ហាញពីស្ថានភាពអាពាហ៍ពិពាហ៍ផ្សេងៗគ្នា។ ការស្រាវជ្រាវនេះមានសំណាកសរុបចំនួន ១៣៥០ នាក់ នៃស្ត្រីដែលមានអាយុចាប់ពី២០ឆ្នាំ ដល់២៤ឆ្នាំ គឺជាចំនួនសរុបនៃអ្នកចូលរួមពិសេសសម្រាប់ការសិក្សា ដែលទទួលបានតាមរយៈវិធីសាស្ត្រជ្រើសរើសសំណាកបែបពហុដំណាក់កាល( multistage sampling procedure) នៅក្នុងខេត្តគោលដៅទាំង៩ មានខេត្តសៀមរាប រតនគិរី ស្ទឹងត្រែង ព្រះវិហារ បាត់ដំបង កំពត ព្រះសីហនុ ព្រៃវែង និងខេត្តតាកែវ។ ស្រុកចំនួនពីរ ត្រូវបានជ្រើសរើសដោយចៃដន្យចេញពីខេត្តនីមួយៗ ដែលយ៉ាងហោចណាស់ មានឃុំចំនួនពីរត្រូវបានជ្រើសរើសចេញពីស្រុកនីមួយៗ ហើយភូមិចំនួនបី ឬច្រើនជាងនេះ ត្រូវបានជ្រើសរើសចេញពីឃុំនីមួយៗ ដើម្បីសម្រេចឱ្យបាននូវទំហំសំណាកអប្បបរមាសម្រាប់ឃុំនីមួយៗ។ ឃុំត្រូវបានបែងចែកជាជនបទឬក្រុង ហើយបន្ទាប់មកត្រូវបានជ្រើសរើសដោយចៃដន្យដើម្បីធ្វើការសិក្សាស្រាវជ្រាវ។

ការស្ទង់មតិត្រូវបានរៀបចំឡើងតាមរយៈ ការបង្កើតកម្រងសំណួរដោយប្រើប្រាស់កម្មវិធី Koboo Tools ក្នុងថេប្លេត (tablet)។ ការប្រមូលទិន្នន័យបែបគុណភាព ធ្វើឡើងតាមរយៈការធ្វើបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ ជាមួយនឹងអ្នកផ្តល់សម្ភាសន៍ចំនួន ១០១នាក់ រួមមានទាំងមេឃុំ មេភូមិ អ្នកដឹកនាំសហគមន៍ អ្នកដឹកនាំយុវជន គ្រូបង្រៀន តំណាងអង្គការមិនមែនរដ្ឋាភិបាល អង្គការមូលដ្ឋានសហគមន៍ គិលានុបដ្ឋាយិកា

វេជ្ជបណ្ឌិត មន្ត្រីនគរបាល និងអ្នកដឹកនាំសាសនា អ្នកព្យាបាលតាមបែបបុរាណ។ វិធីសាស្ត្រយកសំណាកងាយៗត្រូវបានប្រើប្រាស់ដើម្បីជ្រើសរើសអ្នកឆ្លើយតបបទសម្ភាសន៍ អ្នកផ្តល់ព័ត៌មានសំខាន់ៗជាបុគ្គល និងជាក្រុម ដោយសារតែលក្ខណៈនៃការសិក្សាប្រភេទនេះ តម្រូវឱ្យមានការចូលរួមពី មន្ត្រីរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងទៀត។ ការធ្វើបទសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ មានរួមបញ្ចូលនូវបទសម្ភាសន៍ចំនួន១១ ដែលធ្វើឡើងជាមួយនឹងភ្នាក់ងាររដ្ឋាភិបាលសំខាន់ៗ និងអង្គការជាដៃគូពាក់ព័ន្ធនៅក្នុងគម្រោង។ ទន្ទឹមនឹងនេះ ក៏មានការសម្ភាសន៍ជាក្រុម ចំនួន ៤៥ក្រុម ដែលមានអ្នកឆ្លើយតបសម្ភាសន៍ចំនួន ២២៥នាក់ផងដែរ។ ខេត្តនីមួយៗមានចំនួន ៥ក្រុម ដែលមានអ្នកឆ្លើយតបសម្ភាសន៍ចំនួន ២៥នាក់ តំណាងឱ្យក្រុមផ្សេងៗគ្នា៖ ស្ត្រីមានអាយុ (១៨–២៤ឆ្នាំ), ស្ត្រីមានអាយុ(២៥–៣៥ឆ្នាំ), បុរសមានអាយុ(១៨–២៤ឆ្នាំ), បុរសមានអាយុ(២៥–៣៥ឆ្នាំ) ហើយក្រុមដែលរួមបញ្ចូលគ្នារវាងស្ត្រីនិងបុរសមានអាយុ (៣០–៦០ឆ្នាំ)។

**របកគំហើញសំខាន់ៗ៖** របកគំហើញនៃការសិក្សាបង្ហាញថា មានការថយចុះនូវអត្រានៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងនៅកម្ពុជា។ លទ្ធផលនៃការស្ទង់មតិបង្ហាញថា មានសមាមាត្រតិចតួច ពោលគឺ ០.៥០% នៃអ្នកឆ្លើយតបសម្ភាសន៍ បានរៀបអាពាហ៍ ពិពាហ៍នៅមុនពេលមានអាយុ ១៥ឆ្នាំ។ លើសពីនេះទៅទៀត លទ្ធផលនេះមានបំណងបញ្ជាក់ថា អ្នកឆ្លើយសម្ភាសន៍ចំនួន ១៣.៩៣% បានរាយការណ៍ថា ពួកគេទទួលបានការផ្សំផ្គុំឱ្យរៀបអាពាហ៍ពិពាហ៍នៅពេលដែលពួកគេមានអាយុចន្លោះ១៥ឆ្នាំ ដល់ ១៨ឆ្នាំ។ របកគំហើញនៃការសិក្សានេះបង្ហាញឱ្យឃើញថា ស្ត្រីភាគច្រើនពោលគឺ ១៤.៤៤% រៀបអាពាហ៍ពិពាហ៍មុនឈានដល់អាយុ ១៨ ឆ្នាំ។ ភាគរយដែលគួរឱ្យកត់សម្គាល់ ៥០.១៥% នៃអ្នកឆ្លើយតបសម្ភាសន៍ បានរៀបអាពាហ៍ពិពាហ៍នៅអាយុ ១៨ឆ្នាំ ឬច្រើនជាងនេះ។ ចំពោះបុរសវិញ មានតែ ០.២២% ប៉ុណ្ណោះដែលបានរៀបអាពាហ៍ពិពាហ៍នៅមុនអាយុ ១៥ឆ្នាំ ប៉ុន្តែភាគរយយ៉ាងច្រើនគឺ ២.៩៦% បានរៀបអាពាហ៍ពិពាហ៍នៅចន្លោះអាយុពី ១៥ឆ្នាំ ដល់១៨ឆ្នាំ។ បុរសប្រមាណ ៦១.៤១% រៀបអាពាហ៍ពិពាហ៍ក្រោយអាយុ ១៨ ឆ្នាំ។

យោងតាមស្ថានភាពចុះបញ្ជីអាពាហ៍ពិពាហ៍មានអ្នកឆ្លើយតបការសម្ភាសន៍ភាគច្រើន(៦៦.៩៧%) បានបញ្ជាក់ថា ពួកគេមិនបានធ្វើការចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ទៅតាមដំណើរការផ្លូវច្បាប់នោះទេ។ ផ្ទុយមកវិញ មានអ្នកឆ្លើយតបតែ ៣២.៨% ប៉ុណ្ណោះដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ អ្នកចូលរួម ០.២៣% បង្ហាញពីភាពមិនច្បាស់លាស់ ឬខ្វះការយល់ដឹងពាក់ព័ន្ធនឹងបញ្ហាផ្លូវច្បាប់នេះ។

**ការប្រៀបធៀបអត្រាប្រេវ៉ាឡង់នៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងតាមបណ្តាខេត្ត៖** ក្នុងចំណោមខេត្តទាំងប្រាំបួនដែលបានធ្វើការសិក្សានេះ ខេត្តរតនគិរី មានស្ត្រីរៀបអាពាហ៍ពិពាហ៍មុនឈានចូលដល់អាយុ ១៨ ឆ្នាំ ដែលខ្ពស់ជាងគេក្នុងអត្រា ៣៧.៣%។ ខេត្តព្រះវិហារស្ថិតក្នុងកម្រិតខ្ពស់បំផុតទីពីរដែលមានអត្រា ១៦.៧%។ ខេត្តស្ទឹងត្រែង ស្ថិតក្នុងលេខរៀងទី៣ ដែលមានអត្រា ១៤.៧%។ ខេត្តកំពត ស្ថិតក្នុងលេខរៀងទីបួន ដែលមានអត្រា ១៤%។ ខេត្តសៀមរាប ស្ថិតក្នុងលេខរៀងទីប្រាំដែលមានអត្រា ១២%។ ខេត្តព្រៃវែង ស្ថិតក្នុងលេខរៀងទីប្រាំមួយ ដែលមានអត្រា ១០.៧%។ ខេត្តព្រះសីហនុស្ថិតក្នុងលេខរៀងទីប្រាំពីរដែលមានអត្រា ៩.៣%។ ខេត្តបាត់ដំបង ស្ថិតក្នុងលេខរៀងទីប្រាំបី ដែលមានអត្រា ៨%។ ខេត្តតាកែវមានអត្រាទាបបំផុត ៧.៣%។

**មូលហេតុជាឫសគល់ ឬកត្តាពាក់ព័ន្ធនាំឱ្យមានអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង ៖** ការសិក្សាបង្ហាញថា កត្តាជំរុញឱ្យមានអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍

ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង រួមមានទីតាំងភូមិសាស្ត្រ សេដ្ឋកិច្ចរបស់គ្រួសារ ភាពក្រីក្រ វិសមភាពសេដ្ឋកិច្ចសង្គម ជាតិសាសន៍ សាសនា ការអប់រំ ការបោះបង់ការសិក្សា កង្វះចំណេះដឹង វិសមភាពយេនឌ័រ ការមានផ្ទៃពោះក្នុងវ័យជំទង់ បទដ្ឋានសង្គមនិងវប្បធម៌ កង្វះការអនុវត្តច្បាប់ និងឥទ្ធិពលនៃអ៊ីនធឺណិត និងបណ្តាញសង្គម។ ស្ត្រីដែលរស់នៅក្នុងខេត្តភូមិភាគឦសាន ជាពិសេសនៅខេត្តរតនគិរីប្រឈមមុខនឹងហានិភ័យរៀបអាពាហ៍ពិពាហ៍មុនអាយុ១៨ ឆ្នាំមានចំនួនច្រើនជាងស្ត្រីដែលរស់នៅខេត្តសៀមរាប។ ស្ត្រីដែលជាជនជាតិដើមនិងជនជាតិភាគតិច និងមិនមែនជាពុទ្ធសាសនិកប្រឈមមុខនឹងបញ្ហាអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងខ្ពស់គួរឱ្យកត់សម្គាល់។ កម្រិតអប់រំរបស់ម្តាយក៏ជាកត្តាមួយដ៏សំខាន់ ព្រោះស្ត្រីដែលមានកម្រិតអប់រំត្រឹមមធ្យមសិក្សាបឋមភូមិ ប្រឈមមុខខ្ពស់ទៅនឹងនឹងការរៀបអាពាហ៍ពិពាហ៍មុនអាយុ១៨ឆ្នាំ។ កម្រិតអប់រំរបស់ម្តាយក៏បានដើរតួនាទីយ៉ាងសំខាន់ផងដែរ ព្រោះស្ត្រីដែលមានម្តាយមានកម្រិតអប់រំត្រឹមមធ្យមសិក្សាបឋមភូមិ ប្រឈមមុខខ្ពស់នឹងការរៀបអាពាហ៍ពិពាហ៍មុនអាយុ១៨ឆ្នាំ។ វិសមភាពយេនឌ័រ ជាកត្តាបរិបទដ៏សំខាន់មួយនៅក្នុងសង្គមដែលមានការរើសអើងលើការកំណត់តួនាទីរបស់ក្មេងស្រី និងស្ត្រីនៅក្នុងគ្រួសារ និងសហគមន៍។ ការមានផ្ទៃពោះនៅវ័យជំទង់ ជាកត្តាជំរុញមួយផ្សេងទៀតនៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង ដោយសារឪពុកម្តាយអាចជ្រើសរើសឱ្យកូនរៀបអាពាហ៍ពិពាហ៍ ព្រោះវាអាចបណ្តាលឱ្យខូចកេរ្តិ៍ឈ្មោះ និងកិត្តិយសរបស់គ្រួសារ។ បទដ្ឋានសង្គម និងវប្បធម៌ ដូចជាការអនុវត្តពីបុរាណ សកម្មភាពផ្លូវភេទក្នុងវ័យក្មេងដែលបរិបទសង្គមអាចទទួលយកបាន និងសម្ពាធពីមិត្តភក្តិ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើអាយុរៀបអាពាហ៍ពិពាហ៍របស់ក្មេងស្រី ជាពិសេសនៅតំបន់ជនបទ។ ភាពក្រីក្រជាកាតាលីករដ៏សំខាន់មួយទៀតសម្រាប់អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង ព្រោះជារឿយៗគ្រួសារដាក់សម្ពាធលើក្មេងស្រីឱ្យរៀបអាពាហ៍ពិពាហ៍ដើម្បីជួយសម្រាលបន្ទុកហិរញ្ញវត្ថុ។ ការមិនទទួលបានការអប់រំផ្លូវការ ជាពិសេសការអប់រំចំណេះទូទៅ សុខភាពបន្តពូជ សុខភាពផ្លូវភេទ និងការពន្យារកំណើត ជាកត្តាសំខាន់ដែលរួមចំណែកដល់ អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងជាពិសេសនៅក្នុងសហគមន៍ដាច់ស្រយាល។ កង្វះការយល់ដឹងផ្នែកច្បាប់និងការអនុវត្តច្បាប់ប្រឆាំងនឹងអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍វ៉ិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង មិនសូវមានប្រសិទ្ធភាព ក៏ជាកត្តាមូលដ្ឋានមួយដែរ។ ជាចុងក្រោយវេទិកាទំនាក់ទំនងតាមអ៊ិនធឺណិត និងឌីជីថលអាចមានសក្តានុពលរួមចំណែកយ៉ាងខ្លាំងទៅលើ អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង ព្រោះនៅក្នុងប្រទេសកម្ពុជា យុវជនរស់នៅជនបទភាគច្រើនខ្វះចំណេះដឹងផ្នែកឌីជីថល និងជំនាញទំនាក់ទំនងតាមអ៊ិនធឺណិត។ របកគំហើញនៃការសិក្សានេះបង្ហាញថា នៅក្នុងអំឡុងការផ្ទុះជំងឺកូវីដ១៩ ជំងឺនេះមិនបានដើរតួចូលរួមចំណែកដល់ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធនៅវ័យក្មេងឡើយ។

**ផលប៉ះពាល់នៃការរៀបការវ័យក្មេង៖** ការរៀបការវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង មានផលប៉ះពាល់យ៉ាងខ្លាំងទៅលើកត្តាជាច្រើន រួមមានការមានផ្ទៃពោះនៅវ័យក្មេង ផលវិបាកផ្នែកសុខភាព ភាពក្រីក្រ និងចំណូលទាប ការកើតមានអំពើហិង្សាក្នុងគ្រួសារ ការរំលោភលើសិទ្ធិ និងសេរីភាពរបស់ក្មេងស្រី ការទទួលបានការអប់រំ ការផ្តាច់ទំនាក់ទំនងពីសង្គម ការចូលរួមក្នុងនាមជាពលរដ្ឋ និងការចូលរួមការងារសង្គម។ អាពាហ៍ពិពាហ៍នៅវ័យក្មេង បង្កើនភាពងាយរងគ្រោះលើសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ការរំលូតកូន និងបញ្ហាសម្រាលកូន ហើយបន្តធ្វើឱ្យសេដ្ឋកិច្ចនៅតែមានបញ្ហាប្រឈម តាមរយៈការកាត់បន្ថយការវិនិយោគលើការអប់រំ និងសុខភាពកុមារីវ័យក្មេង បន្តធ្វើឱ្យផលិតភាពនៅមានកម្រិតទាប និងបន្តវដ្តនៃភាព

ក្រីក្រ។ ការមានផ្ទៃពោះនៅវ័យជំទង់ធ្វើឱ្យមានភាពឯកោក្នុងសង្គម និងបញ្ហាប្រឈមក្នុងការចិញ្ចឹមកូនដែលបណ្ដាលឱ្យមានការកាត់បន្ថយការចូលរួមក្នុងកិច្ចការសហគមន៍ និងវេទិកាធ្វើសេចក្ដីសម្រេចចិត្ត។

ការវិភាគអំពីអន្តរាគមន៍លើអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធនៅវ័យក្មេងពីមុនៗ៖ ការសិក្សាបានបង្ហាញថា ការគ្រប់គ្រង អភិបាលកិច្ច និងអន្តរាគមន៍ពីភាគីពាក់ព័ន្ធចំពោះអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធនៅវ័យក្មេង នៅមានកម្រិត និងខ្វះខាតនៅឡើយ។ ការអនុវត្តនៅមិនទាន់មានប្រសិទ្ធភាពខ្ពស់ដើម្បីឆ្លើយតបនឹងបញ្ហា។ ហេតុនេះតម្រូវឱ្យមានយុទ្ធសាស្ត្រពហុភាគីពាក់ព័ន្ធ និងវិធីសាស្ត្រដ៏ទូលំទូលាយដើម្បីទប់ស្កាត់បញ្ហាទាំងនេះ។

ភាពខ្វះចន្លោះផ្នែកច្បាប់៖ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ និងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារនៃព្រះរាជាណាចក្រកម្ពុជា គ្រប់គ្រងលើចំណុចជាច្រើននៃការរៀបអាពាហ៍ពិពាហ៍នៅប្រទេសកម្ពុជាដោយរួមមានលក្ខណៈវិនិច្ឆ័យសម្រាប់សិទ្ធិទទួលបាន ដំណើរការចុះបញ្ជី ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការបែងចែកការចំណាយក្នុងគ្រួសារ។ ទោះយ៉ាងណាអត្រាប្រេវ៉ាឡង់នៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធនៅវ័យក្មេង នៅតែជាកង្វល់ដោយសារតែការអនុវត្តច្បាប់ដែលមានស្រាប់មិនទាន់ពេញលេញនៅឡើយ។ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៩៤៨ ប្រការ ២ មានភាពខ្វះចន្លោះក្នុងការដែលអនុញ្ញាតឱ្យអនីតិជនអាចរៀបអាពាហ៍ពិពាហ៍បានដោយមានការទទួលស្គាល់ ដឹងឮពីឪពុកម្ដាយ ឬអាណាព្យាបាលរបស់ពួកគេ។ យ៉ាងណាមិញ ជាការចាំបាច់គឺត្រូវធ្វើវិសោធនកម្មទៅលើមាត្រា ៩៤៨ ប្រការ២ នៃក្រមរដ្ឋប្បវេណី ដើម្បីបង្កើតឱ្យមានច្បាប់រៀបអាពាហ៍ពិពាហ៍នៅអាយុតិចបំផុត ១៨ឆ្នាំ ដើម្បីលុបបំបាត់នូវតម្រូវការនៃការទទួលស្គាល់អាយុរៀបអាពាហ៍ពិពាហ៍។ ក្របខណ្ឌច្បាប់ក៏នៅខ្វះបទប្បញ្ញត្តិសម្រាប់គូស្វាមីភរិយាដែលជ្រើសរើសមិនចុះបញ្ជីអាពាហ៍ពិពាហ៍នៅការិយាល័យអត្រានុកូលដ្ឋាន ឬសម្រាប់គូស្វាមីភរិយាដែលបានចែកផ្លូវគ្នាដោយពុំមានដីកាលែងលះស្របច្បាប់។ ការមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ជាផ្លូវការ ឬដំណើរការលែងលះ អាចមានផលវិបាកយ៉ាងខ្លាំង ជាពិសេសចំពោះស្ត្រីដែលរៀបអាពាហ៍ពិពាហ៍មុនអាយុ។

**ភាពខ្វះចន្លោះផ្នែកគោលនយោបាយ៖** រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងភាគីពាក់ព័ន្ធនានាបានអនុវត្តតាមគោលនយោបាយ និងកិច្ចអន្តរាគមន៍ដើម្បីដោះស្រាយបញ្ហាអាពាហ៍ពិពាហ៍នៅវ័យក្មេង និងអំពើហិង្សាលើកុមារ ប៉ុន្តែនៅមិនទាន់មានយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិដើម្បីដោះស្រាយបញ្ហានេះឱ្យកាន់តែមានប្រសិទ្ធភាពនៅឡើយ។

**សេចក្ដីសន្និដ្ឋាន៖** ការសិក្សាបង្ហាញថា ប្រេវ៉ាឡង់នៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធនៅវ័យក្មេង មានការថយចុះ ប៉ុន្តែនៅតែជាបញ្ហាដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា។

**អនុសាសន៍៖** ដោយផ្អែកតាមរបកគំហើញនៃការសិក្សា ខាងក្រោមនេះជាអនុសាសន៍ដែលអាចអនុវត្តបានក្នុងគោលបំណងពន្លឿនកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយ និងកាត់បន្ថយបញ្ហាអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធនៅវ័យក្មេង នៅក្នុងប្រទេសកម្ពុជា៖

១) **អភិវឌ្ឍន៍ផែនការសកម្មភាពជាតិដ៏ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយមួយដែលកំណត់នូវបញ្ហាអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធនៅវ័យក្មេង** ជារឿងសំខាន់ណាស់ ក្នុងការអនុវត្តយុទ្ធសាស្ត្រជាប្រព័ន្ធ និងមានភាគីពាក់ព័ន្ធច្រើនចូលរួម។

២) **រាជរដ្ឋាភិបាលកម្ពុជាផ្តល់កញ្ចប់ថវិកាដោយឡែក**សម្រាប់ការអនុវត្តផែនការសកម្មភាពជាតិដើម្បីដោះស្រាយ និងទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង ។

៣) **ពង្រឹងការសម្របសម្រួលអន្តរវិស័យក្នុងការដោះស្រាយបញ្ហា**អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង **ទាំងថ្នាក់ជាតិ និងថ្នាក់តំបន់**
ដើម្បីដោះស្រាយបញ្ហានេះឱ្យមានប្រសិទ្ធភាព និងឱ្យបានទូលំទូលាយ ក្រសួងកិច្ចការនារី ទទួលបានការស្នើសុំឱ្យបន្តតួនាទីក្នុងនាមជាអ្នកដឹកនាំនៅក្នុងការបង្កើតគណៈកម្មការអន្តរក្រសួងរួមមាន ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងអភិវឌ្ឍន៍ជនបទ ជាដើម។

៤) **ពង្រឹងច្បាប់ និងគោលនយោបាយ ដោយបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងគោលនយោបាយ** ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ និងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីការពារសុខុមាលភាពរបស់ក្មេងស្រី និងស្ត្រី គួរត្រួតពិនិត្យឡើងវិញ និងធ្វើវិសោធកម្មលើនីតិវិធីច្បាប់មួយចំនួនដែលមានស្រាប់ដើម្បីបំពេញនូវភាពខ្វះចន្លោះ។ មាត្រា៩៤៨ ប្រការ ២ មានភាពខ្វះចន្លោះក្នុងការដែលអនុញ្ញាតឱ្យអនីតិជនអាចរៀបអាពាហ៍ពិពាហ៍បានដោយមានការទទួលស្គាល់ ដឹងឮពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេ។ យ៉ាងណាមិញ វាមានភាពចាំបាច់ក្នុងការធ្វើវិសោធនកម្មទៅលើមាត្រា ៩៤៨ ប្រការ ២ នៃក្រមរដ្ឋប្បវេណី ដើម្បីបង្កើតឱ្យមានច្បាប់រៀបអាពាហ៍ពិពាហ៍នៅអាយុតិចបំផុត ១៨ឆ្នាំ ដើម្បីលុបបំបាត់នូវតម្រូវការនៃការទទួលស្គាល់អាយុរៀបអាពាហ៍ពិពាហ៍។ ក្របខណ្ឌច្បាប់ក៏នៅខ្វះបទប្បញ្ញត្តិសម្រាប់គូស្វាមីភរិយាដែលជ្រើសរើសមិនចុះបញ្ជីអាពាហ៍ពិពាហ៍នៅការិយាល័យ អត្រានុកូលដ្ឋាន ឬសម្រាប់គូស្វាមីភរិយាដែលបានបែកផ្លូវគ្នាដោយពុំមានដីកាលែងលះស្របច្បាប់។ ការមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ជាផ្លូវការ ឬដំណើរការលែងលះអាចមានផលវិបាកយ៉ាងខ្លាំង ជាពិសេសចំពោះស្ត្រីដែលរៀបអាពាហ៍ពិពាហ៍មុនអាយុ។

៥) **ផ្តល់ជំនួយដល់ក្មេងស្រី និងស្ត្រីដែលរងផលប៉ះពាល់ដោយសារអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង**
គោលបំណងនេះអាចសម្រេចទៅបានតាមរយៈការអនុវត្តក្របខណ្ឌប្រកបដោយការគាំទ្រ និងយោគយល់ដែលនឹងពង្រីកឱ្យដល់វិស័យជាច្រើនដូចជាវិស័យសង្គមកិច្ច ច្បាប់ សេដ្ឋកិច្ច និងចិត្តសាស្ត្រ។ យុទ្ធសាស្ត្រដែលបានណែនាំ ធ្វើឡើងក្នុងគោលបំណងដើម្បីអាចទទួលបានការគាំទ្រលើការប្រឹក្សា ផ្លូវច្បាប់ និងសុខភាពផ្លូវចិត្ត ស្របពេលដែលកំពុងតែធ្វើការសម្របសម្រួលលើការផ្តល់សេវាថែទាំកុមារដែលទទួលបានជំនួយពីរដ្ឋ ដើម្បីជួយលើកកម្ពស់ការបន្តការសិក្សារបស់ពួកគេ ឬចូលធ្វើការងារដែលទទួលបានប្រាក់កម្រៃត្រឹមត្រូវ។ លើសពីនេះ ជារឿងដែលសំខាន់ផងដែរ ក្នុងការផ្តល់អាហារូបករណ៍ដល់ក្មេងស្រីដែលកំពុងតែស្ថិតនៅក្នុងវ័យរៀបអាពាហ៍ពិពាហ៍ និងកំពុងស្ថិតនៅក្នុងបរិបទនេះនៅតំបន់ជនបទ និងនៅតំបន់ជនជាតិភាគតិច។ម្យ៉ាងវិញទៀត ជាការសំខាន់ផងដែរក្នុងការបង្កើតគំនិតផ្តួចផ្តើមក្នុងការលើកកម្ពស់ផ្នែកសេដ្ឋកិច្ចដែលផ្តោតលើក្មេងស្រី ជាពិសេសអ្នកដែលកំពុងស្ថិតនៅក្នុងទំនាក់ទំនងរៀបអាពាហ៍ពិពាហ៍។ ការសម្រេចគោលបំណងនេះ នឹងជួយឱ្យយើងទទួលស្គាល់តាមរយៈការអនុវត្តក្របខណ្ឌប្រកបដោយការគាំទ្រ និងយោគយល់ដែលនឹងពង្រីកដល់វិស័យជាច្រើនដូចជា វិស័យសង្គម ច្បាប់ សេដ្ឋកិច្ច និងចិត្តសាស្ត្រ។

៦) **បង្កើតទាំងវេទិកាផ្លូវការ និងក្រៅផ្លូវការសម្រាប់ក្មេងស្រី** ដើម្បីឱ្យពួកគេចែករំលែកបទពិសោធន៍ តម្រូវការ បំណងប្រាថ្នា និងដំណោះស្រាយរបស់ពួកគេ ក៏ដូចជាធានាថាពួកគេមានអារម្មណ៍ថាខ្លួនមានអំណាចលើការសម្រេចចិត្តដែលមានឥទ្ធិពលលើពួកគេ។

៧) **បង្កើនការយល់ដឹងជាសាធារណៈ** ជាពិសេសក្នុងចំណោមមាតាបិតា គ្រូបង្រៀន អ្នកដឹកនាំសហគមន៍ និងក្មេងជំទង់ ទាក់ទងនឹងបញ្ហាមូលដ្ឋាន និងផលប៉ះពាល់នៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធនៅវ័យក្មេង។ ការទាញចំណាប់អារម្មណ៍លើកត្តាដែលប៉ះពាល់ដល់ស្ត្រី និងក្មេងស្រីរងគ្រោះក្នុងបញ្ហានេះគឺជារឿងសំខាន់។ ដើម្បីបង្កើនការយល់ដឹងឱ្យមានប្រសិទ្ធភាពត្រូវមានផែនការច្បាស់លាស់មួយដែលប្រើប្រាស់វេទិកា និងបណ្តាញផ្សេងៗ ដែលទាំងនេះអាចរួមបញ្ចូលការដាក់ឱ្យបង្រៀននៅក្នុងថ្នាក់រៀន រៀបចំការពិភាក្សាដោយបើកចំហសម្រាប់សហគមន៍ រៀបចំកម្មវិធីជជែកតាមវិទ្យុ បង្កើតភាពយន្តអប់រំ និងផ្ទាំងរូបភាពសម្រាប់បណ្តាញសង្គម និងការរៀបចំកម្មវិធីផ្សាយដែលមានតារាល្បីៗនិងអ្នកមានឥទ្ធិពលលើប្រព័ន្ធផ្សព្វផ្សាយសង្គមចូលរួម។ យើងអាចបង្កើនឥទ្ធិពលនិងពង្រីកវិសាលភាពរបស់យុទ្ធនាការលើកកម្ពស់ការយល់ដឹងនេះបានតាមរយៈការអនុវត្តយុទ្ធសាស្ត្រផ្សេងៗជាច្រើន។

៨) **អនុវត្តការធ្វើអន្តរាគមន៍កម្រិតសហគមន៍សម្រាប់ការផ្លាស់ប្តូរបទដ្ឋានសង្គម និងវប្បធម៌** ដោយការលើកទឹកចិត្តឱ្យមានការសន្ទនាក្នុងចំណោមប្រជាជនគ្រប់វ័យអំពីមូលហេតុ និងផលប៉ះពាល់អវិជ្ជមាននៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង ជាមួយក្មេងប្រុស ក្មេងស្រី ស្ត្រី បុរស គ្រួសារ និងអ្នកដឹកនាំសហគមន៍។ ការពិភាក្សាទាំងនេះក៏ផ្តល់ជាវេទិកាសម្រាប់ការផ្សព្វផ្សាយចំណេះដឹងអំពីច្បាប់ដែលមានគោលបំណងការពារសិទ្ធិកុមារី និងការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ការពិភាក្សានៅតាមសហគមន៍ មានគោលបំណងលើកកម្ពស់ការផ្លាស់ប្តូរបទដ្ឋានសង្គម និងឥរិយាបថអវិជ្ជមាន។ ប្រើប្រាស់ធនធាន និងស្ថាប័នក្នុងស្រុកដែលមានស្រាប់ ដូចជាមណ្ឌលសហគមន៍ អង្គការគ្រួសារ អាជ្ញាធរមូលដ្ឋាន និងកន្លែងសម្អាត ក៏អាចជួយពន្លឿនការអនុវត្តកិច្ចអន្តរាគមន៍នេះបានផងដែរ។

៩) **លើកកម្ពស់ការអប់រំអំពីសិទ្ធិមនុស្ស** ដោយផ្តោតជាពិសេសលើសិទ្ធិកុមារ សិទ្ធិស្ត្រី និងសិទ្ធិទាក់ទងនឹងអាពាហ៍ពិពាហ៍

គំនិតផ្តួចផ្តើមនេះគួរតែផ្តោតជាពិសេសទៅលើក្មេងជំទង់ និងមនុស្សចាស់ ជាពិសេសក្មេងស្រីដោយមានគោលបំណងលើកកម្ពស់ការយល់ដឹង និងផ្លាស់ប្តូរការយល់ឃើញរបស់សង្គមទាក់ទងនឹងអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង និងតួនាទីរបស់ក្មេងស្រី និងស្ត្រីនៅក្នុងសង្គម។

១០) **ផ្តល់សិទ្ធិអំណាចដល់ក្មេងស្រី និងលើកកម្ពស់លទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព** តាមរយៈយុទ្ធសាស្ត្រជាច្រើន រួមមានការផ្តល់ព័ត៌មានឱ្យបានហ្មត់ចត់ ការធានាលទ្ធភាពទទួលបានការអប់រំផ្លូវការដ៏ល្អសម្រាប់ពួកគេ ការផ្តល់ឱកាសសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបង្កើតបណ្តាញគាំពារ ដើម្បីបង្កើតបរិយាកាសលើកទឹកចិត្តដល់ក្មេងស្រីឱ្យនៅរៀន បន្តការសិក្សា និងបន្តស្វែងរកគោលដៅការងាររបស់ពួកគេ។

១១) **ផ្តល់ចំណេះដឹងផ្នែកឌីជីថល ការអប់រំអំពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ការពន្យារកំណើត ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ សុវត្ថិភាពឌីជីថល និងការបណ្តុះបណ្តាលអំពីទំនាក់ទំនងតាមអ៊ិនធឺណិត** សម្រាប់ក្មេងស្រី និងក្មេងប្រុសវ័យជំទង់ ទាំងអ្នកដែលកំពុងសិក្សានិងអ្នកដែលបានបោះបង់ការសិក្សា។

# បញ្ជីអក្សរកាត់

| | |
|---|---|
| CEFMU | អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធវ័យក្មេង |
| SRHR | សិទ្ធិ និងសុខភាពផ្លូវភេទ សុខភាពបន្តពូជ |
| UN | អង្គការសហប្រជាជាតិ |
| CBO | អង្គការសហគមន៍មូលដ្ឋាន |
| CEMF | អាពាហ៍ពិពាហ៍នៅវ័យក្មេង និងអាពាហ៍ពិពាហ៍ដោយបង្ខំ |
| CSO | អង្គការសង្គមស៊ីវិល |
| FGD | ការធ្វើបទសម្ភាសជាក្រុម |
| KII | បទសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| UDHR | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| CRC | អនុសញ្ញាស្តីពីសិទ្ធិកុមារ |

# បញ្ជីតារាង

តារាងទី 1: បុគ្គលិកលក្ខណៈសង្គម-ប្រជាសាស្ត្ររបស់អ្នកឆ្លើយតប ....26
តារាងទី 2: យោងតាមគំនិតរបស់អ្នក ក្មេងស្រីអាយុក្រោម ១៨ ឆ្នាំបានរៀបការនៅក្នុងសហគមន៍របស់អ្នក.... 30
តារាងទី 3: យោងតាមគំនិតរបស់អ្នក ក្មេងប្រុសអាយុក្រោម ១៨ ឆ្នាំបានរៀបការនៅក្នុងសហគមន៍របស់អ្នក ....31
តារាងទី 4: ការអនុវត្តការរៀបការក្មេងស្រីមុនអាយុ ១៥ ឆ្នាំនៅក្នុងសហគមន៍របស់អ្នកចាប់តាំងពីឆ្នាំមុន ....31
តារាងទី 5: ការអនុវត្តការរៀបការក្មេងប្រុសមុនអាយុ ១៥ ឆ្នាំនៅក្នុងសហគមន៍របស់អ្នកចាប់តាំងពីឆ្នាំមុន ....32
តារាងទី 6: ការអនុវត្តការរៀបការក្មេងស្រីមុនអាយុ ១៨ ឆ្នាំនៅក្នុងសហគមន៍របស់អ្នកចាប់តាំងពីឆ្នាំមុន ....32
តារាងទី 7: ការអនុវត្តការរៀបការក្មេងប្រុសមុនអាយុ ១៨ឆ្នាំនៅក្នុងសហគមន៍របស់អ្នកចាប់តាំងពីឆ្នាំមុន....33
តារាងទី 8: ការរៀបការដែលផ្តល់ការការពារដល់ក្មេងស្រី ....33
តារាងទី 9: បម្រែបម្រួលរូបរាងកាយគឺជាសញ្ញាបង្ហាញថា ក្មេងស្រីបានត្រៀមខ្លួនរួចរាល់សម្រាប់ការរៀបការ ....33
តារាងទី 10: ក្មេងស្រីអាយុក្រោម ១៨ ឆ្នាំមានកូនច្រើនជាងក្មេងស្រីដែលមានអាយុលើសពី ១៨ ឆ្នាំ....34
តារាងទី 11: ការរៀបការជាមួយក្មេងស្រីអាយុក្រោម ១៨ ឆ្នាំធានាបាននូវភាពបរិសុទ្ធ (ព្រហ្មចារីយ៍) នៅថ្ងៃរៀបមង្គលការ ....34
តារាងទី 12: ការរៀបការជាមួយកុមារអាយុក្រោម ១៨ ឆ្នាំ ជួនកាលអាចជាមធ្យោបាយរកប្រាក់យកទៅសងបំណុល ....35
តារាងទី 13: នៅក្នុងសហគមន៍របស់អ្នកក៏មានទម្លាប់ជូនថ្លៃបណ្ណាការដែរ....35
តារាងទី 14: ថ្លៃបណ្ណាការនឹងមានតម្លៃទាប នៅពេលកុមារកាន់តែមានអាយុក្មេង និងមានការអប់រំតិចតួច ....35
តារាងទី 15: ក្មេងស្រីដែលមានអាយុច្រើនជាង ១៨ ឆ្នាំហើយមិនទាន់រៀបការគឺជាបន្ទុករបស់គ្រួសារ....36
តារាងទី 16: ការរៀបការមុនអាយុ ១៨ ឆ្នាំគឺជាការតម្រូវដោយសាសនា ឬប្រពៃណី ....36
តារាងទី 17: ក្មេងស្រីវ័យជំទង់ភាគច្រើនចូលចិត្តរៀបការមុនអាយុ ១៨ ឆ្នាំ....37
តារាងទី 18: អត្រាប្រេវ៉ាឡង់នៃ CEFMU មុនអាយុ ១៥ ឆ្នាំ និង ក្រោមអាយុ ១៨ ឆ្នាំ....37
តារាងទី 19: អត្រាប្រេវ៉ាឡង់នៃ CEFMU តាមខេត្ត....39
តារាងទី 20: អត្រាប្រេវ៉ាឡង់នៃស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍មុនអាយុ ១៨ ឆ្នាំជាលក្ខណៈប្រជាសាស្ត្រ ....40
តារាងទី 21: លក្ខណៈនៃការរៀបអាពាហ៍ពិពាហ៍....41
តារាងទី 22: ឫសគល់/កត្តាពាក់ព័ន្ធនៃ CEFMU....42
តារាងទី 23: ចំណេះដឹងរបស់អ្នកឆ្លើយតបអំពី CEFMU ....47
តារាងទី 24: ការប្រៀបធៀបផលប៉ះពាល់នៃ CEFMU លើស្ត្រីដែលរៀបអាពាហ៍ពិពាហ៍មុន និងក្រោយអាយុ ១៨ ឆ្នាំ ...51
តារាងទី 25: ផលប៉ះពាល់នៃ CEFMU លើការមានផ្ទៃពោះវ័យក្មេង ....52
តារាងទី 26: ការយល់ឃើញលើផលប៉ះពាល់នៃ CEFMU លើហានិភ័យចំពោះសុខភាពកូនរបស់ពួកគេ....53
តារាងទី 27: ផលប៉ះពាល់នៃ CEFMU លើសុខភាព....53
តារាងទី 28: ផលប៉ះពាល់នៃ CEFMU លើប្រាក់ចំណូល/ភាពក្រីក្រ....54
តារាងទី 29: ផលប៉ះពាល់នៃ CEFMU លើឱកាសការងារ....55
តារាងទី 30: ផលប៉ះពាល់នៃ CEFMU លើអំពើហិង្សាក្នុងគ្រួសារ....55
តារាងទី 31: ប្រភេទនៃអំពើហិង្សា ....56
តារាងទី 32: ផលប៉ះពាល់របស់ CEFMU លើសេរីភាព និងសិទ្ធិរបស់ក្មេងស្រី ....57
តារាងទី 33: ផលប៉ះពាល់នៃ CEFMU លើការអប់រំ....57
តារាងទី 34:ផលប៉ះពាល់របស់ CEFMU លើការចូលរួមក្នុងសង្គម និងនយោបាយ ....58
តារាងទី 35: បទពិសោធន៍របស់អ្នកឆ្លើយតបក្នុងកិច្ចអន្តរាគមន៍ពាក់ព័ន្ធនឹង CEFMU....59

# I. សាវតារនៃការសិក្សា

អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធវ័យក្មេង ជាការអនុវត្តដែលបង្កគ្រោះថ្នាក់ ជាការរំលោភបំពានសិទ្ធិកុមារ ក្មេងស្រី និងស្ត្រី និងជាឧបសគ្គមូលដ្ឋានចំពោះការអភិវឌ្ឍរបស់មនុស្ស។ នៅក្នុងករណីជាក់លាក់ ការអនុវត្តបែបនេះក៏អាចបង្កើតជាអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)។ លើសពីនេះ ការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងក៏មានទំនាក់ទំនងទៅនឹងការមានផ្ទៃពោះនៅវ័យក្មេង។ ការរៀបការនៅ វ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង មានផលប៉ះពាល់ជាអវិជ្ជមានលើក្មេងស្រី និងស្ត្រីវ័យក្មេង ដែលដាក់កម្រិតទៅលើការអប់រំ ការចូលរួមក្នុងសង្គម និងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច ការរំលោភបំពានលើសិទ្ធិផ្លូវភេទ និងសិទ្ធិសុខភាពបន្តពូជ រឹតត្បិតលើស្វ័យភាពរបស់ពួកគេ និងនាំឱ្យមានហានិភ័យនៃអំពើហិង្សាកើនឡើង។ ការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធវ័យក្មេង បង្កគ្រោះថ្នាក់ និងគំរាមកំហែងដល់អាយុជីវិតចំពោះក្មេងស្រី និងស្ត្រី ក៏ដូចជាបង្កផលវិបាកដល់គ្រួសារ សហគមន៍ និងសង្គម។

ទាំងក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងមហាសន្និបាតអង្គការសហប្រជាជាតិអនុម័តលើសេចក្តីសម្រេចស្តីពីការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងរៀងរាល់ពីរឆ្នាំម្តង។ សេចក្តីសម្រេចនេះ ទទួលស្គាល់ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងថា ជាការអនុវត្តដែលបង្កគ្រោះថ្នាក់មួយ ដែលរំលោភបំពានសិទ្ធិមនុស្សរបស់ស្ត្រី និងក្មេងស្រី ហើយសេចក្តីសម្រេចនេះបង្កើតបានជាតួនាទី និងទំនួលខុសត្រូវរបស់រដ្ឋភាគីនៃអង្គការសហប្រជាជាតិ និងតួអង្គពាក់ព័ន្ធផ្សេងទៀតនៅក្នុងការបញ្ឈប់ការអនុវត្តបែបនេះ។ សេចក្តីសម្រេចឆ្នាំ២០១៨ របស់មហាសន្និបាតអង្គការសហប្រជាជាតិ និងសេចក្តីសម្រេចឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សុទ្ធតែលើកឡើងអំពីការការពារ ការលើកកម្ពស់ និងការបំពេញតាមសិទ្ធិរបស់ស្ត្រីដែលរៀបអាពាហ៍ពិពាហ៍រួច ឬរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ។ នៅក្នុងបរិបទមនុស្សធម៌ ទាំងបទដ្ឋានអប្បបរមាសម្រាប់អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងកម្មវិធីសង្គ្រោះបន្ទាន់ និងបទដ្ឋានអប្បបរមាសម្រាប់ការការពារកុមារនៅក្នុងសកម្មភាពមនុស្សធម៌ សុទ្ធតែយោងទៅលើការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង និងគូសបញ្ជាក់អំពីភាពចាំបាច់ក្នុងការធានាធ្វើយ៉ាងណាឱ្យកិច្ចអន្តរាគមន៍នានាដោះស្រាយតម្រូវការជាក់លាក់របស់ក្មេងស្រីវ័យជំទង់និងក្មេងស្រីដែលរៀបអាពាហ៍ពិពាហ៍រួច។

នៅទូទាំងពិភពលោក ក្មេងស្រីម្នាក់ក្នុងចំណោមប្រាំនាក់រៀបអាពាហ៍ពិពាហ៍នៅមុនអាយុ ១៨ ឆ្នាំ និងដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ចាំបាច់ត្រូវមានវឌ្ឍនភាពឱ្យច្រើនជាងទសវត្សមុនរហូតដល់ ១៧ ដង។ ជាលទ្ធផលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ គេបានធ្វើការប៉ាន់ស្មានថាការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង ចំនួន ១៣ លានករណីទៀតនឹងកើតមាននៅចន្លោះឆ្នាំ២០២០ និងឆ្នាំ ២០៣០។ គេយល់ថាអត្រាប្រេវ៉ាឡង់នៃការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងនៅក្នុងអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ១៩ គឺទទួលរងឥទ្ធិពលស្មុគស្មាញពីផលប៉ះពាល់ដែលអាចកើតមានឡើងពីវិធានការដាក់ឱ្យនៅដាច់ដោយឡែក មកលើប្រព័ន្ធអត្រានុកូលដ្ឋានស៊ីវិល ដូចជាការចុះសំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រកំណើត។ ដោយសារតែការអាក់ខាននៅក្នុងការប្រមូលទិន្នន័យអំពីករណីរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង ប្រការនេះអាចនាំឱ្យមានករណីការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង កើតឡើងកាន់តែច្រើន។

ក្រសួងកិច្ចការនារីសហការជាមួយអង្គការភ្លែនអន្តរជាតិកម្ពុជា បានចាប់ផ្តើមសិក្សាស្រាវជ្រាវគ្រប់ជ្រុងជ្រោយមួយស្តីពីការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង នៅក្នុង

ប្រទេសកម្ពុជា។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនៅក្នុងខេត្តគោលដៅ នឹងផ្តល់ជាព័ត៌មានអំពីគោលនយោបាយ ការធ្វើឱ្យប្រសើរឡើងនូវច្បាប់ និងវិធានការដែលអាចអនុវត្តបាន ដើម្បីលុបបំបាត់ការរៀបការនៅវ័យកុមារ ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង នៅក្នុងប្រទេសកម្ពុជា។

## II. គោលបំណងនៃការសិក្សា

### ការសិក្សានេះមានគោលបំណងចម្បងៗដូចជា៖

១) ពិនិត្យអំពីអត្រាប្រេវ៉ាឡង់ មូលហេតុបង្ក និន្នាការ កត្តាជំរុញ និងឥទ្ធិពលនៃការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងនៅមុនអាយុ ១៥ ឆ្នាំ និង ១៨ ឆ្នាំ

២) ត្រួតពិនិត្យឡើងវិញលើច្បាប់និងគោលនយោបាយដែលមានស្រាប់ដែលធ្វើនិយ័តកម្មទៅលើការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង និងការកំណត់ភាពខ្វះចន្លោះផ្នែកច្បាប់ គោលនយោបាយ និងការអនុវត្តផ្សេងៗ

៣) ពិភាក្សាសម្រេចលើផ្នែកវិនិយោគសំខាន់ៗ សម្រាប់សកម្មភាពដែលអាចអនុវត្តបាន និងការកែលម្អ ធ្វើឱ្យប្រសើរឡើងគោលនយោបាយ/យុទ្ធសាស្រ្ត និង/ឬផែនការសកម្មភាពជាតិ អាចដោះស្រាយបញ្ហារៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់

៤) ផ្តល់អនុសាសន៍ដែលអាចអនុវត្តបានក្នុងគោលបំណងពន្លឿនកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់ឱ្យបានកាន់តែមានប្រសិទ្ធភាព។

### ការសិក្សានេះផ្តោតលើសំណួរចម្បងៗដូចខាងក្រោម៖

១) តើអត្រាប្រេវ៉ាឡង់នៃការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងនៅមុនអាយុ ១៥ ឆ្នាំ និង ១៨ ឆ្នាំនៅក្នុងខេត្តគោលដៅមានចំនួនប៉ុន្មាន? តើមាននិន្នាការប្រែប្រួលនៃការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង? តើខេត្តណាដែលមានប្រេវ៉ាឡង់នៃការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធនៅវ័យក្មេងកើនឡើងខ្ពស់លឿនជាងគេ(តើការរីករាលដាលនៃជំងឺកូវីដ-១៩ រួមចំណែកក្នុងការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងដែរឬទេ)?

២) តើមានឫសគល់/កត្តាពាក់ព័ន្ធអ្វីខ្លះនាំឱ្យមានការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធវ័យក្មេង? (ក្នុងករណីអថេរ ឬផ្លាស់ប្តូរបាន អប្បបរមាត្រូវធ្វើតេស្តសាកល្បង រួមទាំងកត្តាភូមិសាស្រ្ត និងប្រជាសាស្រ្តសង្គម៖ ក) កម្រិតវប្បធម៌, ខ) ក្រុមអាយុ, គ) ស្ថានភាពសេដ្ឋកិច្ច,ឃ) ជាតិសាសន៍/ជនជាតិ, ង) ការឈប់រៀន, ច) ចំណេះដឹង និងឥរិយាបថចំពោះការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធវ័យក្មេង, ឆ) ការប្រឈមផ្សេងទៀត(ការមាន ផ្ទៃពោះនៅវ័យជំទង់ អំពើហិង្សាទាក់ទងនឹងយេនឌ័រ ការមានទំនាក់ទំនងស្នេហាក្នុងវ័យសិក្សាជាដើម)

៣) តើការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធវ័យក្មេងមានផលប៉ះពាល់អ្វីខ្លះ? (ត្រូវរួមបញ្ចូលការផ្តោតលើសុខភាព ការការពារ ការអប់រំ និងលទ្ធផលសេដ្ឋកិច្ចចំពោះក្មេងស្រី និងការចូលរួមនៅក្នុងសង្គម)

៤) តើមានវិធានការអ្វីខ្លះដែលបានអនុវត្តកន្លងមក ដើម្បីទប់ស្កាត់ការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង? តើវិធានការណាខ្លះដែលដំណើរការ និងវិធានការណាខ្លះដែលមិនដំណើរការ ព្រមទាំងវិធានការណាខ្លះដែលត្រូវកែលម្អ ពាក់ព័ន្ធនឹងការទប់ស្កាត់ និង

ការឆ្លើយតបទៅនឹងការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធវ័យក្មេង? (សំណួរនេះត្រូវរួមបញ្ចូលការវិភាគអំពីច្បាប់ គោលនយោបាយ ការអនុវត្តច្បាប់ ថវិកា វិធីសាស្ត្រ និងប្រព័ន្ធ/យន្តការដែលបានរៀបចំឡើង ដើម្បីទប់ស្កាត់ការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធនៅវ័យក្មេង និងការអនុវត្តនៅកម្រិតខុសៗគ្នា)

# III. វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ តំបន់នៃការសិក្សា

ការសិក្សានេះគ្របដណ្ដប់លើខេត្តគោលដៅចំនួន៩ មានដូចជា ខេត្តសៀមរាប រតនគិរី ស្ទឹងត្រែង ព្រះវិហារ កំពតបាត់ដំបង ព្រះសីហនុ ព្រៃវែង និងខេត្តតាកែវ។

## ៣.២ សំណាកនិងទំហំសំណាក

**សំណាកសម្រាប់ការសិក្សានេះ រួមមានអ្នកឆ្លើយតបចំនួន ១.៦៨៧ នាក់ ដែលត្រូវបានបែងចែកជាបីក្រុម៖**

១) **ក្រុមទីមួយសម្រាប់ការស្ទង់មតិជាមួយ ស្ត្រីទូទៅចំនួន ១.៣៥០ នាក់ (នៅលីវ រៀបអាពាហ៍ពិពាហ៍ ហើយ និងរស់នៅជាមួយគ្នា) ដែលមានអាយុ ២០ - ២៤ ឆ្នាំ។** ការសិក្សានេះ ត្រូវធ្វើយ៉ាងណាឱ្យស្របតាមសូចនាការនៃគោលបំណងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា "៥.៣ លុបបំបាត់រាល់ទង្វើដែលមានគ្រោះថ្នាក់ ដូចជាការបង្ខំកុមារឱ្យរៀបអាពាហ៍ពិពាហ៍ និងការធ្វើឱ្យមានរបួសស្នាមប្រដាប់បន្តពូជ" សម្រាប់សូចនាករនៃ "៥.៣.១ សមាមាត្ររបស់ស្ត្រី អាយុពី២០ដល់២៤ឆ្នាំដែលបានរៀបអាពាហ៍ពិពាហ៍ឬរស់នៅជាមួយគ្នា មុនអាយុ១៨ឆ្នាំ" ។

២) **ក្រុមទីពីរសម្រាប់ការសម្ភាសន៍អ្នកផ្ដល់ព័ត៌មានសំខាន់ (KIIs)** ជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ចំនួន ៩០ នាក់ (អ្នកឆ្លើយតប ១០ នាក់មកពីតាមបណ្ដាខេត្តនីមួយៗ) ដែលជាមេឃុំ មេភូមិ អ្នកដឹកនាំសហគមន៍ អ្នកដឹកនាំយុវជន គ្រូបង្រៀន អ្នកតំណាងអង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ គិលានុបដ្ឋាយិកា វេជ្ជបណ្ឌិត មន្ត្រីនគរបាល អ្នកដឹកនាំសាសនា គ្រូខ្មែរ។ ការសម្ភាសន៍អ្នកផ្ដល់ព័ត៌មានសំខាន់ក៏រួមបញ្ចូលការសម្ភាសន៍ចំនួន ១១ ជាមួយស្ថាប័នរដ្ឋាភិបាលសំខាន់ៗនិងអង្គការដៃគូពាក់ព័ន្ធនឹងគម្រោង ។

៣) **ក្រុមទីបីសម្រាប់ការពិភាក្សាក្រុមគោលដៅ (FGDs)** ជាមួយអ្នកឆ្លើយតប ២២៥ នាក់ (អ្នកឆ្លើយតប ២៥ នាក់មកពីតាមបណ្ដាខេត្តនីមួយៗ ឬការពិភាក្សាក្រុមគោលដៅចំនួន ៥ក្រុម ក្នុងមួយខេត្ត) ដែលជាស្ត្រី (អាយុ១៨-២៤ ឆ្នាំ) បុរស (អាយុ១៨-២៤ ឆ្នាំ) និងក្រុមចម្រុះបុរស និងស្ត្រី (អាយុ ៣៦-៦០ ឆ្នាំ)។

ការគណនាទំហំសំណាកបែងចែកតាមខេត្ត ដែលបានទាញយកទិន្នន័យពីប្រព័ន្ធគ្រប់គ្រងទិន្នន័យប្រជាជនឃុំ(២០២០) ដោយប្រើប្រាស់រូបមន្តដែលបានស្នើឡើងនៅក្នុងការស្រាវជ្រាវ ដែលចាំបាច់នៅក្នុងលក្ខខណ្ឌយោងនៃគម្រោង។

## ៣.៣ វិធីសាស្ត្រជ្រើសរើសសំណាក

- ដោយសារតែសំណាកចំនួន១.៣៥០ នាក់ ដែលជាស្ត្រីមានអាយុចន្លោះពី ២០ ទៅ ២៤ ឆ្នាំ ជាក្រុមប្រជាជនពិសេស អ្នកឆ្លើយតបសម្រាប់ការសិក្សានេះ ត្រូវបានកំណត់យកតាមរយៈនីតិវិធីជ្រើសរើស

សំណាកពហុដំហាននៅក្នុងខេត្តទាំងប្រាំបួនមានខេត្តសៀមរាប រតនគិរី ស្ទឹងត្រែង ព្រះវិហារ បាត់ដំបង កំពត ព្រះសីហនុ ព្រៃវែង និងខេត្តតាកែវ។ ស្រុកចំនួនពីរ គឺត្រូវបានជ្រើសរើសដោយចៃដន្យចេញពីខេត្តនីមួយៗ ឃុំយ៉ាងតិចចំនួនពីរគឺត្រូវបានជ្រើសរើសចេញពីស្រុកនីមួយៗ សហគមន៍បី ឬច្រើន ត្រូវបានជ្រើសរើសចេញពីឃុំនីមួយៗ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវទំហំសំណាកអប្បបរមាសម្រាប់ឃុំនីមួយៗ។ ឃុំនានា ត្រូវបានចាត់ក្រុមជាឃុំជនបទ ឬទីក្រុង និងបន្ទាប់មកត្រូវបានជ្រើសរើសដោយចៃដន្យសម្រាប់ការអង្កេត។

- វិធីសាស្ត្រជ្រើសរើសសំណាកបែបកាលានុវត្តត្រូវបានយកមកប្រើប្រាស់សម្រាប់ការជ្រើសរើសអ្នកឆ្លើយតបការសម្ភាសន៍ អ្នកផ្តល់ព័ត៌មានសំខាន់ និងការពិភាក្សាក្រុមគោលដៅ ដោយសារតែលក្ខណៈនៃការសិក្សានេះទាមទារឱ្យមានមន្ត្រីរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងទៀតចូលរួមសិក្សា។

## ៣.៤ វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សានេះអនុវត្តយកទាំងវិធីសាស្ត្របែបបរិមាណ និងបែបគុណភាពដែលរួមបញ្ចូលការត្រួតពិនិត្យឯកសារ ការស្ទង់មតិ ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ (KIIs) និងការពិភាក្សាជាក្រុម (FGDs)។

១) **ការត្រួតពិនិត្យឯកសារ៖** ការសិក្សានេះបានប្រើប្រាស់ព័ត៌មានពីការត្រួតពិនិត្យឯកសារ ដែលមានស្រាប់ដូចជារបាយការណ៍ គោលនយោបាយ និងឯកសារពាក់ព័ន្ធទៅនឹងការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង។ គោលបំណងចម្បងនៃការត្រួតពិនិត្យនេះគឺដើម្បីកំណត់រកព័ត៌មានដែលមានស្រាប់ និងកំណត់ត្រាពាក់ព័ន្ធ ដើម្បីស្វែងរកភាពខ្វះចន្លោះ និងដើម្បីផ្តល់សុពលភាពសម្រាប់វិធីសាស្ត្រនៃការស្រាវជ្រាវ និងឧបករណ៍ប្រមូលទិន្នន័យ។ ដំណាក់កាលនេះ ផ្តល់ជាព័ត៌មានសម្រាប់ការកែសម្រួលសំណួរសំខាន់ៗនៃការស្ទង់មតិ ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ និងការពិភាក្សាជាក្រុមជាមួយភាគីពាក់ព័ន្ធ។

២) **ការស្ទង់មតិ៖** ទិន្នន័យបែបបរិមាណត្រូវបានប្រមូលពីកម្រងសំណួរដែលមានរចនាសម្ព័ន្ធដោយប្រើប្រាស់ថែប្លេតជាមួយកម្មវិធី Koboo Tools។

៣) **ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ និងការពិភាក្សាជាក្រុម៖** ទិន្នន័យបែបគុណភាពត្រូវបានប្រមូលពីការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ និងការពិភាក្សាជាក្រុម។ ចំពោះការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់សំណួរត្រូវបានរៀបចំឡើងទុកជាមុននិងត្រូវបានប្រើប្រាស់ដើម្បីដឹកនាំដល់ការប្រមូលទិន្នន័យ។ ការពិភាក្សាជាក្រុមអនុវត្តតាមការណែនាំដូចគ្នាទៅនឹងការណែនាំសម្រាប់ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ ដែលបានរៀបចំឡើងទុកជាមុន។

៤) **សិក្ខាសាលាផ្តល់សុពលភាព៖** សិក្ខាសាលាផ្តល់សុពលភាពនៃលទ្ធផលការសិក្សាជាមួយមន្ត្រីនៃក្រសួងកិច្ចការនារី អង្គការភ្លែនអន្តរជាតិកម្ពុជា និងភាគីពាក់ព័ន្ធផ្សេងៗ។

## ៣.៥ ការគ្រប់គ្រង និងវិភាគទិន្នន័យ

- ចំពោះការស្ទង់មតិបែបបរិមាណ កម្មវិធី Koboo Tools ត្រូវបានយកមកប្រើប្រាស់សម្រាប់ការប្រមូលទិន្នន័យដើម្បីសន្សំសំចៃពេលវេលា និងកាត់បន្ថយកំហុសនានា។ បន្ទាប់មក ទិន្នន័យនឹងត្រូវទាញចូលទៅក្នុងកម្មវិធី MS Excel កំណត់លេខកូដ សម្អាត ត្រួតពិនិត្យ និងពិនិត្យរកភាពត្រឹមត្រូវមុនពេលទាញចេញនិងវិភាគនៅក្នុងកម្មវិធី STATA ១៦ (StataCorp, រដ្ឋតិចសាស់សហរដ្ឋអាមេរិក) ដើម្បីធ្វើការវិភាគ។ ការធ្វើតេស្តស្ថិតិបែបពណ៌នាត្រូវបានប្រើប្រាស់ដើម្បីគណនារកមធ្យម និងគម្លាត(SD) សម្រាប់អថេរជាចំនួនលេខ និងប្រេកង់សម្រាប់អថេរឈ្មោះមីណាល់ និងអរឌីណាល់ដើម្បីពណ៌នាអំពីលក្ខណៈនៃសំណួរ។ ការ

ធ្វើតេស្ត χ២ ឬការធ្វើតេស្ត Fisher ត្រូវបានយកមកប្រើប្រាស់ជាការរៀបចំអថេរបែបប្រភេទ និងការធ្វើតេស្ត Student's t-test សម្រាប់អថេរដែលមានការវិវត្តជាបន្តបន្ទាប់ដើម្បីអាចធ្វើការប្រៀបធៀបមធ្យមនៃក្រុមចំនួនពីរ (ហៅម្យ៉ាងទៀតថាការប្រៀបធៀបម្តងមួយគូ (pairwise comparison)។ តម្លៃ p ដែលមានមុខពីរដែលតូចជាង០.០៥ ត្រូវបានចាត់ទុកថាជាចំណុចសំខាន់នៃស្ថិតិ។ គំរូរ៉ឺគ្រេស្យុងឡូជីស្ទិក (Logistic regression model) ក៏បានយកមកប្រើប្រាស់ ដើម្បីកំណត់រកកត្តាពាក់ព័ន្ធឯករាជ្យទៅនឹងការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង។

- ចំពោះការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ (KIIs) និងការពិភាក្សាជាក្រុម ការសម្ភាសន៍គឺត្រូវបានកត់ត្រាដោយប្រើប្រាស់ឧបករណ៍ថតសំឡេង ដោយមានការអនុញ្ញាតពីអ្នកចូលរួម។ អ្នកសម្ភាសន៍ធ្វើការកត់ត្រាសម្រាប់ការពិភាក្សាជាមួយអ្នកឆ្លើយតបដែលមិនអនុញ្ញាតចំពោះការថតសំឡេង។ អ្នកសម្ភាសន៍ម្នាក់ៗ មានកំណត់ត្រាសង្ខេបអំពីការចុះសម្ភាសន៍មួយក្នុងទម្រង់ស្តង់ដារតាមប្រធានបទសម្រាប់ការប្រមូលទិន្នន័យបែបគុណភាព។ ការវិភាគខ្លឹមសារតាមប្រធានបទ ត្រូវបានអនុវត្តដោយប្រើប្រាស់ទិន្នន័យបែបគុណភាព។ លទ្ធផលរកឃើញពីផ្នែកនៃការវិភាគនេះ គឺត្រូវបានយកទៅប្រើប្រាស់ ដើម្បីបញ្ជាក់ឡើងវិញអំពីគុណភាព និងភាពរឹងមាំនៃអ្វីដែលបានរកឃើញនៅក្នុងផ្នែកបរិមាណនិងផ្តល់ការពន្យល់បកស្រាយ និងមូលហេតុបន្ថែមចំពោះរបកគំហើញសំខាន់ៗណាមួយ។

## ៣.៦ ក្រមសីលធម៌

- ពិធីសារស្រាវជ្រាវនេះ ត្រូវបានត្រួតពិនិត្យ និងអនុម័តដោយគណៈកម្មាធិការសីលធម៌ជាតិ សម្រាប់ការស្រាវជ្រាវសុខភាព (NECHR) នៅថ្ងៃទី ២០ ខែមីនា ឆ្នាំ២០២៣ មុនពេលធ្វើការប្រមូលទិន្នន័យ។
- ទិន្នន័យត្រូវបានប្រមូលដោយក្រុមអ្នកប្រមូលទិន្នន័យដែលបានទទួលការបណ្តុះបណ្តាលអំពីលក្ខណៈនៃការសិក្សា ការប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យ ការប្រើប្រាស់ទម្រង់ស្នើសុំការអនុញ្ញាតនិងក្រមប្រតិបត្តិសម្រាប់អ្នកប្រមូលទិន្នន័យ។ ដោយសារតែលក្ខណៈនៃប្រធានបទនេះ អ្នកអង្កេតការសម្ភាសន៍ជាស្ត្រី នឹងធ្វើការសម្ភាសន៍ជាមួយអ្នកឆ្លើយតបជាស្ត្រី។
- អ្នកចូលរួមក្នុងការសិក្សាទាំងអស់ទទួលបានការជូនដំណឹងអំពីគោលបំណងនៃការសិក្សានេះ ការរក្សាព័ត៌មានសម្ងាត់នៃការឆ្លើយតបរបស់ពួកគាត់និងការប្រើប្រាស់ព័ត៌មានសម្រាប់ការសិក្សានេះ។ អ្នកចូលរួមទាំងអស់សុទ្ធតែបានស្នើសុំការអនុញ្ញាតដោយផ្ទាល់មាត់ មុនពេលធ្វើការសម្ភាសន៍ទទួលបានការជម្រាបប្រាប់ពួកគាត់ថា ការចូលរួមនេះធ្វើឡើងតាមការស្ម័គ្រចិត្ត ដោយមានសិទ្ធិក្នុងការបញ្ឈប់ការសម្ភាសន៍ ឬមិនឆ្លើយសំណួរនៅពេលណាក៏បាន។ ឈ្មោះ ឬរូបថតរបស់អ្នកឆ្លើយតប គឺមិនបានប្រមូល ឬប្រើប្រាស់នៅក្នុងរបាយការណ៍នេះឡើយ។ អ្នកអង្កេតការសម្ភាសន៍ គឺទទួលបានការបណ្តុះបណ្តាល និងបានទទួលការណែនាំអំពីការប្រមូលទិន្នន័យប្រកបដោយក្រមសីលធម៌និងការស្នើសុំការអនុញ្ញាតដែលមានព័ត៌មានគ្រប់គ្រាន់ នៅមុនពេលធ្វើការប្រមូលទិន្នន័យ។
- ការសម្ភាសន៍នេះ ត្រូវបានធ្វើឡើងនៅទីតាំងឯកជន ដើម្បីធានាបាននូវឯកជនភាពដែលសមាជិកគ្រួសារដទៃទៀតមិនអាចស្តាប់ឮអំពីអ្វីដែលកំពុងពិភាក្សានោះទេ។
- ដើម្បីរក្សាការសម្ងាត់ គ្រប់ទិន្នន័យដើមទាំងអស់ គឺត្រូវបានរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព ដែលមានតែអ្នកស្រាវជ្រាវប៉ុណ្ណោះមានសិទ្ធិចូលប្រើប្រាស់។ កំណត់ត្រាអាត់សំឡេងពីការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ និងការពិភាក្សាជាក្រុម នឹងត្រូវបំផ្លាញចោលបន្ទាប់ពីបញ្ចប់ការសិក្សានេះជាស្ថាពរ ហើយប្រតិចារិកជាលាយលក្ខណ៍អក្សរ និងទិន្នន័យបែបបរិមាណផ្សេងៗទៀត ក៏នឹងត្រូវផ្តល់ជូនដល់ភាគីពាក់ព័ន្ធសំខាន់ៗផងដែរ បន្ទាប់ពីបានដកចេញនូវព័ត៌មានកំណត់អត្តសញ្ញាណពីទិន្នន័យទាំងនោះរួចរាល់។

## ៣.៧ វិសាលភាព និងដែនកំណត់នៃការសិក្សា

ការសិក្សាផ្ដោតលើសំណួរសំខាន់ៗដែលបានគ្រោងទុកនៅក្នុងផ្នែកគោលបំណងនៃការសិក្សា។ ដែនកំណត់អនុវត្តទៅលើខេត្តជាក់លាក់ចំនួន ៩ មានខេត្តសៀមរាប រតនគិរី ស្ទឹងត្រែង ព្រះវិហារ បាត់ដំបង កំពត ព្រះសីហនុ ព្រៃវែង និងខេត្តតាកែវ។ ក្រុមមនុស្សគោលដៅចម្បងនៅក្នុងការសិក្សាជាក្មេងស្រីវ័យជំទង់ (នៅលីវ រៀបការ ឬបានរួមរស់ជាប្ដីប្រពន្ធ) ដែលមានអាយុពី ២០-២៤ឆ្នាំ។ ការសិក្សានេះមានគោលបំណងសម្របទៅតាមកម្មវត្ថុនៃ CSDG "៥.៣ លុបបំបាត់នូវការអនុវត្តដែលមានផលអវិជ្ជមានទាំងអស់ដូចជាអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការប៉ះពាល់លើប្រដាប់ភេទស្ត្រីពិសេសគឺផ្ដោតលើសូចនាករ "៥.៣.១ ចំនួនស្ត្រីអាយុពី ២០-២៤ឆ្នាំ ដែលបានរៀបអាពាហ៍ពិពាហ៍ ឬរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធមុនអាយុ ១៨ឆ្នាំ"។ យ៉ាងណាមិញ ក្មេងប្រុសមិនមែនជាក្រុមមនុស្សគោលដៅចម្បងនៅក្នុងការសិក្សានេះទេ។ យោងទៅតាមវិសាលភាពនៃការសិក្សា មិនមានការសិក្សាស៊ីជម្រៅចំពោះផលប៉ះពាល់នៃកូវីត ១៩ ទៅលើការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធនៅវ័យក្មេងនោះទេ។

# IV. របកគំហើញ និងការវិភាគ

## ៤.១ របកគំហើញពីការត្រួតពិនិត្យលើទិន្នន័យដែលមានស្រាប់

### ៤.១.១ បញ្ញត្តិគោល និង និយមន័យ

យោងតាមអង្គការយូនីសេហ្វ "**អាពាហ៍ពិពាហ៍នៅវ័យកុមារ**" សំដៅទៅលើការរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធ ទោះជាផ្លូវការ ឬមិនផ្លូវការក្ដីរវាងកុមារចំនួនពីរនាក់ ឬកុមារម្នាក់ជាមួយនឹងមនុស្សពេញវ័យម្នាក់មុនពេលមានអាយុ ១៨ឆ្នាំ។[1]

"**អាពាហ៍ពិពាហ៍នៅវ័យកុមារ**" គឺជាពាក្យប្រើសម្រាប់ពណ៌នាអំពីការរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធដោយស្របច្បាប់ ឬតាមបែបប្រពៃណី ដែលមានបុគ្គលម្នាក់មានអាយុតិចជាង ១៨ឆ្នាំ។ យោងទៅតាម ក្រុមប្រឹក្សាសិទ្ធិមនុស្សបានឱ្យដឹងថា ការរៀបអាពាហ៍ពិពាហ៍នៅវ័យកុមារក៏សំដៅទៅលើការរៀបអាពាហ៍ពិពាហ៍ដែលប្ដីប្រពន្ធមួយគូនោះមានអាយុត្រឹម ១៨ឆ្នាំ ឬច្រើនជាងនេះ ប៉ុន្តែមានកត្តាផ្សេងទៀតដែលធ្វើឱ្យពួកគេមិនទាន់បានត្រៀមខ្លួនរួចរាល់ដើម្បីទទួលយកការរៀបអាពាហ៍ពិពាហ៍នោះ ដូចជា កត្តាវិវឌ្ឍនៃរូបរាងកាយ អារម្មណ៍ ការរួមភេទ និងផ្លូវចិត្តរបស់ពួកគេ ឬ កង្វះខាតព័ត៌មានពាក់ព័ន្ធទៅនឹងជម្រើសនៃជីវិតរបស់មនុស្សម្នាក់។[2]

"**អាពាហ៍ពិពាហ៍ដោយបង្ខំ**" ដែលដៃគូម្ខាង ឬដៃគូទាំងសងខាង ដោយមិនគិតពីអាយុ មិនបានផ្ដល់ ឬមិនមានលទ្ធភាពផ្ដល់ការយល់ព្រមពេញលេញ និងមានសេរីភាពចំពោះការរៀបអាពាហ៍ពិពាហ៍/ការផ្សំផ្គុំ និងមិនអាចផ្ដាច់ទំនាក់ទំនងអាពាហ៍ពិពាហ៍បាន រួមទាំងសម្ពាធ ឬការគាបសង្កត់ពីសង្គម ឬគ្រួសារ។ អាពាហ៍ពិពាហ៍ដោយបង្ខំ អាចរួមបញ្ចូលនូវការបង្ខិតបង្ខំរាងកាយ ផ្លូវចិត្ត ឬហិរញ្ញវត្ថុ ព្រមទាំងអាចកើតឡើងនៅក្នុងកាលៈទេសៈជាច្រើនទម្រង់ ដូចជាការជួញដូរមនុស្ស ឬការរៀបអាពាហ៍ពិពាហ៍ដោយការផ្សំផ្គុំទុកជាមុន

---

[1] https://www.unicef.org/protection/child-marriage

[2] របាយការណ៍ ឆ្នាំ២០១៤ របស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស A/HRC/២៦/២២ វាក្យខណ្ឌ ៥.
https://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session២៦/Pages/ListReports.aspx

និងការរៀបអាពាហ៍ពិពាហ៍តាមទម្លាប់។ មនុស្សពេញវ័យក៏ទទួលរងនូវអាពាហ៍ពិពាហ៍ដោយបង្ខំផងដែរ ដូច្នេះ មិនមែនអាពាហ៍ពិពាហ៍ដោយបង្ខំទាំងអស់គឺសុទ្ធតែជាការរៀបអាពាហ៍ពិពាហ៍នៅវ័យកុមារទាំងអស់នោះទេ។

**ការរស់នៅជាប្តីប្រពន្ធ** សំដៅទៅលើការរៀបអាពាហ៍ពិពាហ៍ក្រៅផ្លូវការ ឬការរស់នៅជាប្តីប្រពន្ធដោយសេរី ដែលជាទូទៅត្រូវបានគេអនុវត្តនៅអាមេរិកឡាទីន និងការីប៊ីន (ប៉ុន្តែក៏មានការកើនឡើងនៃការអនុវត្តដូចនេះនៅបណ្តាប្រទេសផ្សេងៗនៅលើពិភពលោកផងដែរ) និងដែលមានចេតនា និងគោលបំណងដូចគ្នាទាំងស្រុងទៅនឹងការរៀបអាពាហ៍ពិពាហ៍ផ្លូវការ ទោះបីជាមិនមានបញ្ជាក់អំពីស្ថានភាពស្របច្បាប់នៃអាពាហ៍ពិពាហ៍ក៏ដោយ។ ការរួមរស់ជាមួយគ្នាទាំងនេះ ជារឿយៗគឺមិនត្រូវបានរដ្ឋ ឬអាជ្ញាធរសាសនាទទួលស្គាល់ជាផ្លូវការនោះទេ ដែលធ្វើឱ្យមានការលំបាកក្នុងការគិតគូរទៅលើករណីទាំងនេះ និងពិបាកក្នុងការប្រមូលទិន្នន័យឱ្យបានគ្រប់គ្រាន់អំពីបញ្ហានេះ។ មានពាក្យខុសៗគ្នាជាច្រើនដែលបានប្រើប្រាស់ ដើម្បីកំណត់ឈ្មោះ និងពណ៌នាអំពីការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ រួមទាំងការរស់នៅជាមួយគ្នាដោយព្រមព្រៀង ឬដោយស្ម័គ្រចិត្តផ្ទាល់ខ្លួន ការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធនៅវ័យក្មេង និងអនីតិសង្វាស។[3]

អង្គការផ្លែនអន្តរជាតិកម្ពុជា កំណត់និយមន័យ**ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង** ជាអាពាហ៍ពិពាហ៍ ឬការរស់នៅជាប្តីប្រពន្ធក្រៅផ្លូវការណាមួយ មិនថាស្ថិតនៅក្រោមច្បាប់រដ្ឋប្បវេណី សាសនា ឬទំនៀមទម្លាប់ក្តី មាន ឬមិនមានការចុះបញ្ជីផ្លូវការក្តី មិនថាភាគីម្ខាង ឬភាគីទាំងសងខាងមានអាយុក្រោម ១៨ ឆ្នាំក្តី និង/ឬមិនថាមានការយល់ព្រមពេញលេញ និងដោយសេរីពីភាគីម្ខាង ឬភាគីទាំងពីរក្តី។[4]

យោងតាមអង្គការ យូអិនអេហ្វភីអេ (UNFPA) តំបន់អាស៊ី និងប៉ាស៊ីហ្វិកបង្ហាញឱ្យឃើញអំពីទម្រង់ខុសៗគ្នាជាច្រើននៃអាពាហ៍ពិពាហ៍នៅវ័យក្មេង និងការរស់នៅជាប្តីប្រពន្ធវ័យក្មេង។ អង្គការ យូអិនអេហ្វភីអេ (UNFPA) បានចាត់ថ្នាក់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការរស់នៅជាប្តីប្រពន្ធវ័យក្មេងទៅជាបីទម្រង់ខុសៗគ្នា ដូចជា ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងតាមប្រពៃណី(បង្ខំ/ផ្សំផ្គុំជាមុន) ការរៀបអាពាហ៍ពិពាហ៍ ឬអនីតិសង្វាសកើតពីទំនាក់ទំនងស្នេហារវាងដៃគូ និងការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងតាមស្ថានភាពពិសេស។[5]

**១) ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងតាមប្រពៃណី (បង្ខំ/ផ្សំផ្គុំជាមុន)**

- ជាទូទៅមិនមានការយល់ព្រម
- អាចនឹងពាក់ព័ន្ធជាមួយនឹងបណ្ណាការ ឬថ្លៃចូលស្តីដណ្តឹង និងកម្រិតជីវភាពខុសគ្នាខ្លាំងរវាងប្តីប្រពន្ធ និង
- ជំរុញដោយបទដ្ឋានយេនឌ័រដែលកំណត់និងឱ្យតម្លៃដល់ក្មេងស្រីដែលជាអ្នកបង្កើតកូន និងជាម្តាយ ស្របពេលដែលការឱ្យតម្លៃខ្ពស់ទៅលើភាពបរិសុទ្ធ ឬព្រហ្មចារីរបស់ក្មេងស្រីមុនពេលរៀបអាពាហ៍ពិពាហ៍ដោយមានការមាក់ងាយគួរឱ្យកត់សម្គាល់ទៅលើឥរិយាបថ និងការមានផ្ទៃពោះមុនពេលរៀបអាពាហ៍ពិពាហ៍។

**២) ការរៀបអាពាហ៍ពិពាហ៍ ឬអនីតិសង្វាសកើតពីទំនាក់ទំនងស្នេហារវាងដៃគូ**

---

[3] អង្គការផ្លែនអន្តរជាតិ និងដៃគូ (ឆ្នាំ២០១៩)។ ការប្រយុទ្ធប្រឆាំងនឹងការយល់ខុសៈ កម្មវិធីអភិវឌ្ឍន៍ផ្នែកផ្លូវភេទ និងយេនឌ័រដើម្បីលុបបំបាត់ការរៀបការនៅវ័យកុមារ អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមរស់ជាប្តីប្រពន្ធវ័យក្មេង។

[4] សេចក្តីសង្ខេបអំពីគោលនយោបាយស្តីពីការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធ (CEFMU) អង្គការផ្លែនអន្តរជាតិកម្ពុជា ឆ្នាំ២០២០ អាចរកបាននៅ https://plan-international.org/uploads/២០២១/០២/glo-cefmu_policy_brief-final-io-eng-jan២១-១.pdf

[5] ភាពចម្រុះនៃប្រភេទនៃការរៀបការនៅវ័យក្មេង ការរៀបការដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅតំបន់អាស៊ីប៉ាស៊ីហ្វិក អង្គការ UNFPA អាចរកបាននៅ https://asiapacific.unfpa.org/sites/default/files/pub-pdf/asrh_factsheet_១_child_marriage_and_early_union.pdf

- ដោយមានការយល់ព្រម និងជាទូទៅមានការព្រមព្រៀងជាមួយដៃគូ
- ប្ដីប្រពន្ធអាចសម្រេចចិត្តរួមរស់ជាមួយគ្នាជាអនីតិសង្វាស ឬរៀបអាពាហ៍ពិពាហ៍មុនគ្រប់អាយុដែលជាផ្នែកមួយនៃទំនាក់ទំនងស្នេហា ឬផ្លូវភេទរបស់ពួកគេ
- ប្រការនេះអាចមើលទៅមានលក្ខណៈសកម្មផ្លូវភេទពេកនៅក្នុងបរិបទនៃបទដ្ឋានសង្គមបែបអភិរក្សនិយម ដែលហាមឃាត់ការរួមសង្វាសមុនពេលរៀបអាពាហ៍ពិពាហ៍
- អាចនាំឱ្យមានការមានផ្ទៃពោះដោយចេតនា ឬអចេតនា ជាមធ្យោបាយមួយក្នុងការចៀសវាងពីការមាក់ងាយពាក់ព័ន្ធនឹងការមានកូនមុនពេលរៀបអាពាហ៍ពិពាហ៍ និង
- បញ្ជាក់អំពីឯករាជ្យភាព និងជម្រើសរបស់ក្មេងស្រី។

៣) ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងតាមស្ថានភាពពិសេស

- មាន ឬមិនមានការយល់ព្រមពីក្មេងស្រី ជាការឆ្លើយតបទៅនឹងការមានផ្ទៃពោះដោយមិនបានព្រាងទុកដោយមិនមានចំណងអាពាហ៍ពិពាហ៍ ឬអំពើហិង្សាផ្លូវភេទ
- អាចជាការរៀបចំផ្សំផ្គុំទុកមុន ឬសម្រេចចិត្តដោយដៃគូផ្ទាល់ និង
- នៅក្នុងបរិបទនៃការជំទាស់ពីផ្នែកសង្គមវប្បធម៌ជាខ្លាំងទៅលើសកម្មភាពផ្លូវភេទនិងការមានផ្ទៃពោះក្រៅចំណងអាពាហ៍ពិពាហ៍ ក្មេងស្រីអាចនឹងទទួលរងសម្ពាធ ឬបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ដើម្បីបញ្ចៀសពីការដាក់ទណ្ឌកម្ម ការមាក់ងាយ និងការរើសអើងពីសង្គម។

## ៤.១.២ លិខិតបទដ្ឋានគតិយុត្តិនិងការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធនៅវ័យក្មេង

### ៤.១.២.១ លិខិតបទដ្ឋានគតិយុត្តិជាតិ និងការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ ដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធនៅវ័យក្មេង

#### បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស។ យោងតាមមាត្រា៣១ រដ្ឋត្រូវតែទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដោយអនុវត្តតាមបញ្ញត្តិនៃធម្មនុញ្ញ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ។ មាត្រា ៣២ ធានាបាននូវសិទ្ធិរស់រានមានជីវិតស្របពេលដែលមាត្រា ៧២ ធានាបាននូវសិទ្ធិសុខភាព ដោយចែងថា "រដ្ឋយកចិត្តទុកដាក់ ដល់ការការពារជំងឺ និងព្យាបាលជំងឺ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ។ មាត្រា ៣១ក៏ពង្រឹងសមភាពចំពោះមុខច្បាប់សម្រាប់ប្រជាជនគ្រប់រូប"មានសិទ្ធិសេរីភាពនិងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនានិន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈ សង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។"មាត្រា ៤៥ ចែងអំពីការលុបបំបាត់ការរើសអើងគ្រប់ទម្រង់ទាំងអស់មកលើស្ត្រី។ បុរស និងស្ត្រីគឺមានសិទ្ធិស្មើគ្នានៅគ្រប់ទិដ្ឋភាពទាំងអស់ ជាពិសេសពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ និងគ្រួសារ។ មាត្រា ៤៦ ផ្ដោតលើការការពារស្ត្រីពីគ្រប់ទម្រង់នៃអំពើហិង្សា និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់ស្ត្រី ព្រមទាំងតម្រូវឱ្យរាជរដ្ឋាភិបាលកម្ពុជា "យកចិត្ត

ទុកដាក់បង្គលក្ខណៈឱ្យនារី ជាពិសេសនារី នៅជនបទដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ។"

យោងតាមមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ អាពាហ៍ពិពាហ៍ត្រូវធ្វើតាមគោលការណ៍ស្ម័គ្រចិត្ត ប្ដីមួយប្រពន្ធមួយ។ បន្ថែមពីនេះទៅទៀត មាត្រា ៤៥ ហាមឃាត់ដាច់ខាតទៅលើការរើសអើងប្រឆាំងនឹងស្ត្រី ដែលផ្ដល់សិទ្ធិដល់ស្ត្រីក្នុងការផ្ដល់ការយល់ព្រមដោយសេរីចំពោះអាពាហ៍ពិពាហ៍ និងមានសិទ្ធិស្មើគ្នានៅក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសអាពាហ៍ពិពាហ៍ និងគ្រួសារ។

រដ្ឋធម្មនុញ្ញក៏ទទួលស្គាល់សិទ្ធិកុមារផងដែរ។ មាត្រា ៤៨ ចែងថា រដ្ឋធានាការក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងនៅក្នុងអនុសញ្ញាស្ដីពីសិទ្ធិកុមារ។ សិទ្ធិទាំងនេះរួមមាន សិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំ សិទ្ធិទទួលបានការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំរបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។

## បទប្បញ្ញត្តិច្បាប់

ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ និងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសាររបស់កម្ពុជាគឺជាបទដ្ឋានគតិយុត្តិសំខាន់ៗនៅក្នុងប្រទេសកម្ពុជា ដែលគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើទិដ្ឋភាពជាច្រើននៃអាពាហ៍ពិពាហ៍។ ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ (ឆ្នាំ១៩៨៩) គ្រប់គ្រង និងការពារចំណងអាពាហ៍ពិពាហ៍ និងគ្រួសារ ដោយមានគោលដៅធានាឱ្យបាននូវការប្រព្រឹត្តចំពោះភាគីទាំងពីរនៅក្នុងចំណងអាពាហ៍ពិពាហ៍ និងគ្រួសារ។ ច្បាប់នេះក៏គូសបញ្ជាក់អំពីភារកិច្ចរបស់ឪពុកម្ដាយក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន ក៏ដូចជាការបណ្ដុះនូវការលូតលាស់ផ្នែកសីលធម៌ និងការអប់រំផងដែរ។ យោងតាមច្បាប់នេះ អាពាហ៍ពិពាហ៍ គឺជា"កិច្ចសន្យាដ៏ឱឡារិកមួយរវាងបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្ដេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់"ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន (យោងតាមមាត្រា ៥ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ អាយុអប្បបរមាដែលស្របច្បាប់សម្រាប់អាពាហ៍ពិពាហ៍គឺបុរសអាយុចាប់ពី ២០ ឆ្នាំឡើង និងនារីចាប់ពីអាយុ ១៨ ឆ្នាំឡើង។ ប៉ុន្តែមានករណី ពិសេសដែលអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ក្រោមអាយុនេះបានដូចជាករណីដែលនារីមានផ្ទៃពោះ ឬមានការអនុញ្ញាតពីឪពុកម្ដាយឬអាណាព្យាបាល។ លើសពីនេះ មាត្រា ២ បានហាមឃាត់ដាច់ខាតនូវអាពាហ៍ពិពាហ៍ដែលគូស្រករនៅក្មេងពេក (ទោះបីជាមិនបានកំណត់អំពីអាយុជាក់លាក់ក្ដី) និងផ្ដន្ទាទោសចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

យោងតាមក្រមរដ្ឋប្បវេណីកម្ពុជា (ឆ្នាំ២០០៧) ទាំងបុរស និងនារីត្រូវតែមានអាយុ១៨ ឆ្នាំទើបអាចមានសមត្ថភាពស្របច្បាប់ក្នុងការកំណត់ដោយឯករាជ្យថាតើពួកគេមានបំណង ឬមិនមានបំណងរៀបអាពាហ៍ពិពាហ៍។ មាត្រា ៩៥៣ នៃក្រមរដ្ឋប្បវេណីអនុញ្ញាតអាពាហ៍ពិពាហ៍របស់អនីតិជនដោយស្ថិតក្រោមលក្ខខណ្ឌពិសេស។ អនីតិជនត្រូវតែមានអាយុយ៉ាងតិច១៦ ឆ្នាំ និងបង្ហាញអំពីបំណងក្នុងការរៀបអាពាហ៍ពិពាហ៍។ លើសពីនេះ ភាគីម្ខាងទៀតត្រូវតែមានអាយុយ៉ាងតិច១៨ឆ្នាំ ហើយអនីតិជនត្រូវតែសុំការព្រមព្រៀងពីឪពុកម្ដាយឬអាណាព្យាបាល។

យោងតាមមាត្រា ៩៥៤ នៃក្រមរដ្ឋប្បវេណី អនីតិជនអាចរៀបអាពាហ៍ពិពាហ៍បាន ប្រសិនបើអនីតិជនមានផ្ទៃពោះ ទោះបីជាពួកគេទាំងពីរសុទ្ធតែមានអាយុក្រោម ១៨ ឆ្នាំក្ដី។ ប៉ុន្តែ អាពាហ៍ពិពាហ៍នេះអនុញ្ញាតទៅបានលុះត្រាណាតែមានការយល់ព្រមពីឪពុកម្ដាយ ឬអាណាព្យាបាល (ដូចមានចែងក្នុងមាត្រា ៩៥៣) ឬប្រសិនបើ

អនីតិជនមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈចាំបាច់ និងឪពុកម្ដាយ ឬអាណាព្យាបាលផ្ដល់ការយល់ព្រម (ដូចមានចែងនៅក្នុងមាត្រា ៩៥៤)។

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តបទប្បញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍ថ្មីនៅថ្ងៃទី ៧ ខែមីនា ឆ្នាំ២០១១ ដើម្បីប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ច ការជួញដូរមនុស្ស និងជំរុញឱ្យមានអាពាហ៍ពិពាហ៍ដោយស្មោះត្រង់។ បទប្បញ្ញត្តិទាំងនេះរួមមានការកំណត់អាយុ និងលក្ខខណ្ឌតម្រូវប្រាក់ចំណូលអប្បបរមាសម្រាប់បុរសដែលជាជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយនារីខ្មែរ។ បទប្បញ្ញត្តិថ្មីទាំងនេះត្រូវបានអនុវត្តនៅកម្ពុជា ដើម្បីទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍បោកបញ្ឆោត និងការជួញដូរមនុស្ស។ វិធានទាំងនេះហាមឃាត់បុរសដែលជាជនបរទេសដែលមានអាយុលើសពី ៥០ ឆ្នាំមិនឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយនារីខ្មែរនៅក្នុងប្រទេសបាននោះទេ។ លើសពីនេះ ជនបរទេសដែលមានចំណូលតិចជាង ២៥៨០ ដុល្លារអាមេរិកក្នុងមួយខែ ក៏មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយនារីក្នុងប្រទេសផងដែរ។ ជាការសំខាន់ណាស់ក្នុងការកត់សម្គាល់ថា ការរឹតត្បិតទាំងនេះមិនអនុវត្តចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងនៅក្រៅប្រទេសកម្ពុជាឡើយ។ [6]

យោងតាមមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី អាពាហ៍ពិពាហ៍ដែលអនុលោមតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារត្រូវបានចាត់ទុកថាមានសុពលភាពស្របច្បាប់សម្រាប់ការចុះបញ្ជីអាពាហ៍ពិពាហ៍ ។ ជាកាតព្វកិច្ច ត្រូវចុះបញ្ជីកំណើតទាំងអស់ជាមួយការិយាល័យ "ឃុំ" ឬសង្កាត់នៅក្នុងរយៈពេល ៣០ ថ្ងៃ ដោយការខកខានមិនបានមកចុះបញ្ជីនឹងត្រូវរងនូវការពិន័យ។ កំណើតដែលមិនមានការចុះបញ្ជី នាំឱ្យមានការរើសអើង និងថែមទាំងរងនូវការបដិសេធសេវាដែលចាំបាច់ដើម្បីបញ្ជាក់ជាភស្តុតាងអំពីសញ្ជាតិ។ យោងតាមមាត្រា ៣ នៃអនុក្រឹត្យលេខ ១០៣ អក.បក ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ប្រជាពលរដ្ឋកម្ពុជា និងជនបរទេសទាំងអស់ដែលស្នាក់នៅក្នុងប្រទេសត្រូវចុះបញ្ជីអត្រានុកូលដ្ឋានរបស់ខ្លួននៅក្នុងសៀវភៅបញ្ជីអត្រានុកូលដ្ឋាន។ ការចុះបញ្ជីទាំងនេះរួមមាន ការចុះសំបុត្របញ្ជីកំណើត មរណភាព និងអាពាហ៍ពិពាហ៍។

## ក្របខណ្ឌទំនៀមទម្លាប់/សាសនា/ប្រពៃណី

ការអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជា អាចនឹងទទួលរងឥទ្ធិពលពីទំនៀមទម្លាប់ សាសនា និងប្រពៃណី។ ករណីនេះអាចរកបាននៅក្នុងមាត្រា ២៣ នៃច្បាប់ស្តីពីកិច្ចសន្យាដែលចែងថា ក្នុងករណីដែលគោលបំណងនៅពីក្រោយប្រការកិច្ចសន្យាមានភាពមិនច្បាស់លាស់ នោះប្រការនៃកិច្ចសន្យានោះត្រូវយល់ស្របតាមប្រពៃណី ឬអនុសញ្ញាក្នុងមូលដ្ឋាន។ ការរៀបអាពាហ៍ពិពាហ៍ដោយផ្សំផ្គុំមុន ដែលជាការអនុវត្តដ៏យូរអង្វែងមួយនៅក្នុងប្រទេសកម្ពុជា មានអត្រាធ្លាក់ចុះជាបណ្តើរៗក្នុងឆ្នាំកន្លងមកនេះ។

ពុទ្ធសាសនា ជាសាសនារបស់រដ្ឋនៅក្នុងប្រទេសកម្ពុជា។ យោងតាមពុទ្ធឱវាទ ឪពុកម្ដាយមានតួនាទីរៀបចំអាពាហ៍ពិពាហ៍សមស្របសម្រាប់កូននិងធានាថាកូនចៅត្រូវបានរៀបចំទុកដាក់ទៅឱ្យគ្រួសារមានផៅសណ្ដានសមរម្យ។ លើសពីនេះ នៅក្នុងសង្គមកម្ពុជា មានការរំពឹងខ្ពស់ឱ្យឪពុកម្ដាយទទួលខុសត្រូវក្នុងការជ្រើសរើស និងរៀបចំអាពាហ៍ពិពាហ៍សម្រាប់កូនរបស់ខ្លួន ដែលជាមធ្យោបាយមួយក្នុងការរក្សាកេរ្តិ៍ឈ្មោះ និងសេចក្តីថ្លៃថ្នូររបស់គ្រួសារ។ កូនមានភារកិច្ចខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពក្នុងការរក្សាកេរ្តិ៍ឈ្មោះឪពុកម្ដាយ ហើយខ្មែរជឿទៅលើការបង្ហាញអំពីកតញ្ញូតាធម៌ចំពោះឪពុកម្ដាយ តាមរយៈការសម្របតាមបំណងប្រាថ្នា ឬការលះបង់របស់ឪពុកម្ដាយ។ ការរៀបអាពាហ៍ពិពាហ៍ទៅកាន់គ្រួសារមានកេរ្តិ៍ឈ្មោះល្អ គឺត្រូវបានគេមើលឃើញថាជាមធ្យោបាយមួយនៃការបង្ហាញអំពីកតញ្ញូតាធម៌ចំពោះឪពុកម្ដាយ ជាពិសេសសម្រាប់នារី។[7]

---

[6] ក្រសួងចេញសេចក្តីព្រមានស្តីពីការរៀបអាពាហ៍ពិពាហ៍នៅក្រៅប្រតេស ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ សារព័ត៌មានខ្មែរថាមស៍ អាចរកបាននៅ https://www.khmertimeskh.com/៥០៧៧៥៦៦៤/ministry-issues-warning-on-overseas-marriages/

[7] ត្រឹង ងា (ឆ្នាំ១៩៧៤) អរិយធម៌ខ្មែរ

## បទប្បញ្ញត្តិច្បាប់ និងទណ្ឌកម្ម

យោងតាមមាត្រា ២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ (ឆ្នាំ១៩៨៩) អំពើនៃការរៀបអាពាហ៍ពិពាហ៍គូស្រករនៅក្មេងពេក ឬអាពាហ៍ពិពាហ៍ដោយបង្ខំ គឺត្រូវបានហាមឃាត់ដាច់ខាត។

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ឆ្នាំ២០០៨) ចែងថា ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធ (CEFMU) គឺជាបទល្មើសនៅក្រោមមាត្រា ១០ ជំពូក ២ នៃច្បាប់នេះ។ មាត្រានេះហាមឃាត់ជាពិសេសទៅលើការនាំយកចេញអនីតិជនដោយមិនស្របច្បាប់ មិនថាជាការរំលោភបំពានអំណាចលើជនរងគ្រោះ ដោយមានគោលបំណងស្វែងរកប្រយោជន៍ ការឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស បង្ខំជនរងគ្រោះឱ្យរៀបអាពាហ៍ពិពាហ៍ ស្មុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងទៀត។

លើសពីនេះ តុលាការកម្ពុជាមានដែនយុត្តាធិការក្នុងការផ្តន្ទាទោសលើបទល្មើសដែលប្រព្រឹត្តនៅក្រៅព្រំប្រទល់ដែនដីកម្ពុជា លុះត្រាណាតែជនរងគ្រោះ ឬជនល្មើសជាជនជាតិកម្ពុជា។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ឆ្នាំ២០០៨) អនុញ្ញាតឱ្យមានការផ្តន្ទាទោសទាំងបទល្មើសជួញដូរមនុស្សក្នុងប្រទេស និងក្រៅប្រទេស។ ច្បាប់នេះ ជាការពង្រឹងបន្ថែម ដោយសារតែច្បាប់នេះផ្តល់នូវនិយមន័យច្បាស់លាស់អំពីបច្ចេកសព្ទសំខាន់ៗ រួមមាន អនីតិជន ការជួញដូរមនុស្ស អំពើពេស្យាចារ ការរួមសង្វាសជាមួយ អនីតិជនអាយុក្រោម ១៥ ឆ្នាំ និងឯកសារសម្ភារៈអាសអាភាសកុមារ។

ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ និងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ គ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព ទៅលើទិដ្ឋភាពមួយចំនួននៃអាពាហ៍ពិពាហ៍ រួមបញ្ចូលលក្ខខណ្ឌអំពីលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការរៀបអាពាហ៍ពិពាហ៍ នីតិវិធីចុះបញ្ជីអាពាហ៍ពិពាហ៍ ការគ្រប់គ្រងទ្រព្យសម្បត្តិរួម និងការបែងចែកចំណាយនានាក្នុង គ្រួសារ។ ក្នុងន័យទូលាយ ច្បាប់កម្ពុជាផ្តល់នូវកិច្ចគាំពារបន្ថែមសម្រាប់ស្ត្រីរៀបអាពាហ៍ពិពាហ៍ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ទ្វេពន្ធភាព និងការចុះចោល។ ក្របខណ្ឌច្បាប់ ក៏គ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពទៅលើផលប៉ះពាល់ នៃការរំលាយចំណងអាពាហ៍ពិពាហ៍ដែលបានទទួលស្គាល់ដោយច្បាប់ផងដែរ។ ទោះជាយ៉ាងណាក្តី ការអនុវត្តជាក់ស្តែងនៃបទប្បញ្ញត្តិទាំងនេះ អាចនឹងនាំឱ្យមានផលវិបាកពាក់ព័ន្ធនឹងយេនឌ័រ ដែលធ្វើឱ្យថយចុះប្រសិទ្ធភាពនៃវិធានការការពារ ជាពិសេសសម្រាប់ស្ត្រី និងក្មេងស្រី។ ឧទាហរណ៍ ក្របខណ្ឌច្បាប់មិនបានរួមបញ្ចូលបញ្ញត្តិដែលគ្រប់គ្រងលើសិទ្ធិ និងទំនួលខុសត្រូវរបស់ប្តីប្រពន្ធដែលធ្វេសប្រហែសមិនចុះសំបុត្រអាពាហ៍ពិពាហ៍ជាផ្លូវការនៅមន្ត្រីអត្រានុកូលដ្ឋាន ឬសិទ្ធិរបស់ប្តី/ប្រពន្ធលែងលះគ្នា ដែលមិនបានស្នើសុំដីកាលែងលះតាមផ្លូវច្បាប់ពីតុលាការ។ ការខកខានមិនចុះសំបុត្រអាពាហ៍ពិពាហ៍ ឬការស្នើសុំដីកាលែងលះតាមផ្លូវច្បាប់ អាចមានផលប៉ះពាល់ធ្ងន់ធ្ងរ ជាពិសេសសម្រាប់ស្ត្រី និងក្មេងស្រី ដែលរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង។ លើសពីនេះ ក្មេងស្រីនៅកម្ពុជា ប្រកាន់ខ្ជាប់តាមទំនៀមទម្លាប់វប្បធម៌ និងទំនៀមទម្លាប់តាំងពីដើមមក ដោយរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង។ យោងទៅតាមទិន្នន័យស្ថិតិផ្តល់ដោយអង្គការយូនីសេហ្វក្នុងឆ្នាំ ២០១៤ បានឱ្យដឹងថាស្ត្រីចំនួន ២% បានរៀបអាពាហ៍ពិពាហ៍មុនពេលដែលពួកគេមានអាយុ ១៥ឆ្នាំ ខណៈពេលដែលស្ត្រី១៨% ត្រូវបានរៀបអាពាហ៍ពិពាហ៍មុនពេលដែលពួកគេឈានចូលដល់អាយុ ១៨ឆ្នាំ។ ដូច្នេះ ជាភស្តុតាងមួយបញ្ជាក់ថាការអនុវត្តច្បាប់នេះនៅមានភាពខ្វះចន្លោះនៅឡើយ។

### ៤.១.២.២ លិខិតបទដ្ឋានគតិយុត្តិអន្តរជាតិនិងការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធនៅវ័យក្មេង

ប្រទេសកម្ពុជាបានអនុម័តយកលិខិតូបករណ៍ស្តីពីសិទ្ធិមនុស្សអន្តរជាតិមួយចំនួន រួមមាន សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ពិធីសារបន្ថែមនៃអនុញ្ញាសញ្ញាស្តីពីសិទ្ធិកុមារការពាក់ព័ន្ធនឹងការលក់កុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាព ឬសម្ភារៈអាសអាភាសកុមារ (ឆ្នាំ២០០០) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធពលរដ្ឋ និងសិទ្ធនយោបាយ។ លិខិតូបករណ៍សិទ្ធិមនុស្សទាំងនេះ ចែងអំពីបទដ្ឋានដែលត្រូវអនុវត្តចំពោះអាពាហ៍ពិពាហ៍ ដោយមានចែងអំពីអាយុ ការយល់ព្រម សមភាពនៅក្នុងអាពាហ៍ពិពាហ៍ និងសិទ្ធិផ្ទាល់ខ្លួន និងសិទ្ធិទ្រព្យសម្បត្តិរបស់ស្ត្រី។

លិខិតូបបទដ្ឋានគតិយុត្តិអន្តរជាតិចម្បងដែលដោះស្រាយបញ្ហាការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្ដីប្រពន្ធនៅវ័យក្មេង (CEFMU) គឺ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស(UDHR) អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(CEDAW) អនុសញ្ញាបន្ថែមស្ដីពីការលុបបំបាត់ទាសភាព ពាណិជ្ជទាសករ និងស្ថាប័ន និងការអនុវត្តស្រដៀងនឹងទាសភាព និងអនុសញ្ញាស្ដីពីការយល់ព្រមលើអាពាហ៍ពិពាហ៍ អាយុអប្បបរមាសម្រាប់អាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍។

សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស (UDHR) មាត្រា ១៦ ចែងថា៖ (១) បុរសនិងស្ត្រីមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារ ដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ ឬសាសនាឡើយ។ បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ក្នុងចំណងអាពាហ៍ពិពាហ៍ និងក្នុងពេលរំលាយអាពាហ៍ពិពាហ៍, (២) អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរី និងពេញលេញ ពីអនាគត ប្ដីប្រពន្ធ ។ បញ្ញត្តិស្រដៀងគ្នា គឺមានរួមបញ្ចូលនៅក្នុងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធពលរដ្ឋ និងសិទ្ធនយោបាយ។[8]

អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) មាត្រា១៦.១ មានចែងពីសមភាពរវាងបុរស និងស្ត្រី៖ (ក) សិទ្ធិដូចគ្នាក្នុងការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ (ខ) សិទ្ធិដូចគ្នាក្នុងការជ្រើសរើសសហព័ទ្ធរបស់ខ្លួនដោយសេរី និងក្នុងការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ តែនៅពេលណាដែលពួកគេ ព្រមព្រៀងគ្នាដោយសេរី និងដោយពេញលេញប៉ុណ្ណោះ។ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស មាត្រា ១៦ ចែងថា៖ ការភ្ជាប់ពាក្យ និងការរៀបអាពាហ៍ពិពាហ៍កូន មិនត្រូវមានអានុភាពផ្លូវច្បាប់ទេ ហើយគេត្រូវចាត់វិធានការចាំបាច់ទាំងអស់ រួមមានការធ្វើច្បាប់ផងដើម្បីកំណត់អាយុអប្បបរមាសម្រាប់អាពាហ៍ពិពាហ៍ ហើយចាំបាច់ត្រូវចុះបញ្ជីអាពាហ៍ពិពាហ៍នៅក្នុងបញ្ជីជាផ្លូវការ។[9]

យោងទៅតាមការត្រួតពិនិត្យខាងលើ អាចសន្និដ្ឋានបានថា ការអនុវត្តផ្លូវច្បាប់មិនទាន់ពេញលេញនៅឡើយ។ ក្នុងក្របខណ្ឌច្បាប់ក៏មានភាពខ្វះចន្លោះដែលពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដែរព្រោះក្របខណ្ឌនោះមិនបានបញ្ចូលលក្ខខណ្ឌដែលនិយាយអំពីសិទ្ធិ និងកាតព្វកិច្ចដៃគូដែលមិនបានចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ស្របច្បាប់នៅក្នុងសៀវភៅបញ្ជីអត្រានុកូលដ្ឋាននោះទេ។ ម្យ៉ាងទៀត ក្របខណ្ឌនេះក៏មិនបាន

---

[8] https://www.un.org/en/about-us/universal-declaration-of-human-rights#:~:text=Everyone%២០is%២០entitled%២០to%២០all,property%២C%២០birth%២០or%២០other%២០status.

[9] https://www.unwomen.org/en/digital-library/publications/២០១៦/១២/cedaw-for-youth#:~:text=The%២០Convention%២០on%២០the%២០Elimination,women's%២០and%២០girls'%២០equal%២០rights.

ដោះស្រាយបញ្ហាសិទ្ធិរបស់ដៃគូដែលបានលែងលះរួច ដោយមានដីកាពីតុលាការបញ្ជាក់ពីការលែងលះ។ កង្វះខាតនីតិវិធីនៅក្នុងការចុះបញ្ជីលើការរៀបអាពាហ៍ពិពាហ៍ ឬការលែងលះ អាចបង្កឱ្យមានបញ្ហានានា ជាពិសេសបង្កឱ្យស្ត្រីវ័យក្មេងត្រូវរៀបអាពាហ៍ពិពាហ៍ទាំងនៅវ័យក្មេង។

## ៤.១.៣ ទិដ្ឋភាពទូទៅនៃការរៀបអាពាហ៍ពិពាហ៍ក្នុងសង្គមកម្ពុជា

ការរៀបអាពាហ៍ពិពាហ៍នៅក្នុងវ័យក្មេង នៅក្នុងប្រទេសកម្ពុជាអាចចាត់ទុកថាជាបទដ្ឋានវប្បធម៌ និងប្រពៃណីជាក់លាក់មួយដែលអនុវត្តនៅក្នុងអាពាហ៍ពិពាហ៍។ យោងតាមឯកសាររបស់អ្នកស្រី ត្រឹង ងា (ឆ្នាំ១៩៧៤) បានឱ្យដឹងថា ស្ត្រីត្រូវបានគេរំពឹងថាមានវប្បធម៌ក្នុងការប្រកាន់ខ្ជាប់នូវបទដ្ឋាន និងទំនៀមទម្លាប់ដែលបានបង្កើតឡើងក្នុងសង្គមកម្ពុជា។[10] ហេតុដូច្នេះ ក្មេងស្រីជនជាតិខ្មែរអនុលោមទៅតាមវប្បធម៌ និងប្រពៃណីក្នុងស្រុក។ បន្ថែមលើសពីនេះ ក៏មានការរំពឹងទុកផងដែរថាកុមារនឹងត្រូវបង្ហាញការដឹងគុណទៅកាន់ឪពុកម្តាយរបស់ពួកគេ ហើយរបៀបមួយដែលអាចបំពេញនូវកាតព្វកិច្ចនេះបានគឺការយល់ព្រមរៀបអាពាហ៍ពិពាហ៍។ ដំណើរការនៃការរៀបចំពិធីអាពាហ៍ពិពាហ៍ក្នុងប្រទេសកម្ពុជាតាមបែបប្រពៃណី ត្រូវមានការចូលរួមចម្បងពីឪពុកម្តាយទាំងសងខាងនៃបុគ្គលដែលត្រូវរៀបអាពាហ៍ពិពាហ៍។ ម្យ៉ាងទៀត ការសម្រេចចិត្តរបស់ឪពុកម្តាយទៅលើរបៀបរៀបចំពិធីគឺដាក់គំនាបទៅលើការសម្រេចចិត្តរបស់ពួកគេ ដើម្បីធានានូវសុខុមាលភាពសង្គមនិងសេដ្ឋកិច្ចនៃគ្រួសារទាំងសងខាង ដែលជាញឹកញាប់ត្រូវធ្វើឡើងមុនពេលពួកគេឈានដល់អាយុពេញវ័យ។

នៅក្នុងសង្គមខ្មែរ មានការរំពឹងទុកពីសង្គមយូរមកហើយ លើការដាក់សម្ពាធលើស្ត្រីវ័យចំណាស់ និងមិនទាន់រៀបអាពាហ៍ពិពាហ៍។ សម្ពាធនេះបន្តបង្ខំឱ្យឪពុកម្តាយ ធ្វើការជំរុញកូនស្រីពួកគាត់រៀបអាពាហ៍ពិពាហ៍នៅអាយុវ័យក្មេង។ នៅក្នុងវប្បធម៌ខ្មែរមានសុភាសិតមួយដែលនិយាយពីសារៈសំខាន់នៃការរៀបអាពាហ៍ពិពាហ៍មុនពេលដែលគេដាក់ងារឱ្យថាជាក្រមុំចាស់។ សុភាសិតនេះបញ្ជាក់ឱ្យដឹងថា ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធដែលកូនក្រមុំមានវ័យចំណាស់ អាចនឹងមានភាពចុះសម្រុងគ្នាតិចជាង បើប្រៀបធៀបជាមួយនឹងការរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធដែលមានវ័យក្មេង។ ខណៈពេលដែលជម្រើសចុងក្រោយអាចនឹងមិនមែនជាជ្រើសរើសដែលពេញចិត្ត នៅតែចាត់ទុកថាអាចទទួលយកបាននៅក្នុងបរិបទសង្គម។ ចុងក្រោយ គួរឱ្យកត់សម្គាល់ថាជាវប្បធម៌យូរលង់ណាស់មកហើយនៅក្នុងសង្គមកម្ពុជា ដែលមានការមិនពេញចិត្តចំពោះកុមារដែលកើតពីឪពុកម្តាយមិនទាន់រៀបអាពាហ៍ពិពាហ៍។ អាស្រ័យហេតុនេះ ក្នុងករណីដែលក្មេងស្រីជំទង់មានផ្ទៃពោះ ពួកគេត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយដៃគូដែលជាបុរស។

## ៤.១.៤ របាយការណ៍ទាក់ទងនឹងអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងនៅប្រទេសកម្ពុជា

ផ្អែកលើរបកគំហើញនៃការស្ទង់មតិប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ដែលធ្វើឡើងក្នុងអំឡុងឆ្នាំ២០២១–២០២២ ត្រូវបានគេសង្កេតឃើញថា ប្រេវ៉ាឡង់នៃអាពាហ៍ពិពាហ៍នៅវ័យកុមារបង្ហាញថាមាននិន្នាការធ្លាក់ចុះ។ សមាមាត្រនៃស្ត្រីរៀបអាពាហ៍ពិពាហ៍មុនអាយុ១៨ឆ្នាំ បានថយចុះយ៉ាងជាក់លាក់ពី២៥% ទៅ១៩% ខណៈដែលតួលេខដែលត្រូវគ្នាសម្រាប់បុរសបានកាត់បន្ថយពី ៩% ទៅ ៦% ។ លើសពីនេះ ប្រេវ៉ាឡង់នៃការរៀបអាពាហ៍ពិពាហ៍មុនអាយុ១៥ឆ្នាំមានការថយចុះបន្តិចបន្តួចពី ២% ទៅ ១.៨% ក្នុងឆ្នាំ ២០២២។[11]

---

[10] ត្រឹង ងា (ឆ្នាំ១៩៧៤) អរិយធម៌ខ្មែរ

11 ការស្ទង់មតិប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) 2021-2023

យោងទៅតាមCDHS(ឆ្នាំ២០២១-ឆ្នាំ២០២២) អាពាហ៍ពិពាហ៍នៅវ័យកុមារ និងអាពាហ៍ពិពាហ៍ដោយបង្ខំ(CEFM)ត្រូវបានរកឃើញថា មានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការមានផ្ទៃពោះក្នុងវ័យជំទង់។ ការស្រាវជ្រាវបង្ហាញថា ប្រមាណជាពីរភាគរយនៃស្ត្រីវ័យក្មេងដែលមានអាយុចន្លោះពី១៥ទៅ១៩ឆ្នាំ បានរៀបអាពាហ៍ពិពាហ៍ មុនពេលដែលពួកគេមានអាយុ១៥ឆ្នាំ។ លើសពីនេះ ក៏សង្កេតឃើញថាមានតិចជាងមួយភាគរយនៃស្ត្រីវ័យក្មេងទាំងនេះដែលបានផ្តល់កំណើត និងមានបទពិសោធន៍ក្នុងការពរពោះនៅក្នុងអាយុនេះ។ ប្រេវ៉ាឡង់នៃស្ត្រីមានផ្ទៃពោះនៅវ័យជំទង់ក្នុងចំណោមស្ត្រីវ័យក្មេងដែលមានអាយុ១៥–១៩ឆ្នាំគឺមាននិន្នាការកើនឡើងទៅតាមកំណើននៃអាយុជាមួយអត្រា១% ក្នុងចំណោមស្ត្រីដែលមានអាយុ១៥ឆ្នាំ ទៅ៣០% ក្នុងចំណោមស្ត្រីដែលមានអាយុ១៩ឆ្នាំ ។ អត្រានៃការរំលូតកូនបង្ហាញពីនិន្នាការកើនឡើង ផ្តើមចេញពីការរំលូតកូនចំនួន៤ដងក្នុងចំណោមស្ត្រី១០០០នាក់ស្ថិតក្នុងក្រុមអាយុ១៥–១៩ឆ្នាំ ហើយអត្រារំលូតកូនខ្ពស់បំផុតគឺ១៤ដងក្នុងចំណោមស្ត្រី១០០០នាក់ ដែលស្ថិតក្នុងក្រុមអាយុ៣៥–៣៩ឆ្នាំ ហើយបន្ទាប់មកមានការធ្លាក់ចុះ។ អត្រានៃការរំលូតកូនពាក់ព័ន្ធទៅនឹងក្រុមអាយុផ្សេងគ្នាដែលមានកើនឡើងតិចតួចក្នុងចំណោមស្ត្រីនៅទីក្រុង បើប្រៀបធៀបទៅនឹងស្ត្រីដែលនៅជនបទ។

បញ្ហានៃការមានផ្ទៃពោះក្នុងវ័យជំទង់ គឺជាបញ្ហាសុខភាពសាធារណៈដ៏សំខាន់ ព្រោះមានជាប់ពាក់ព័ន្ធទៅនឹងកំណើននៃអត្រាឈឺ និងស្លាប់នៃស្ត្រីជាម្តាយវ័យក្មេង និងកូនចៅជំនាន់ក្រោយ។ ការកើតឡើងនៃការផ្តល់កំណើតក្នុងវ័យជំទង់ ពាក់ព័ន្ធទៅនឹងលទ្ធផលសង្គមអវិជ្ជមាន ជាពិសេសពាក់ព័ន្ធជាមួយនឹងលទ្ធផលនៃការសិក្សាអប់រំ។ ម្តាយដែលស្ថិតក្នុងវ័យជំទង់ច្រើនតែមានទំនោរក្នុងការបោះបង់ការសិក្សា។ ក្នុងបរិបទប្រទេសកម្ពុជា គេសង្កេតឃើញថាប្រហែល ៩%នៃស្ត្រីមានអាយុចន្លោះពី១៥ ទៅ១៩ឆ្នាំ មានបទពិសោធន៍ក្នុងការមានផ្ទៃពោះ។ ដោយយោងទៅតាមទិន្នន័យ ស្ត្រីវ័យក្មេងសរុបចំនួន៧% មានបទពិសោធន៍ក្នុងការផ្តល់កំណើតខណៈពេលដែលស្ត្រីវ័យក្មេងចំនួន ៣%កំពុងពរពោះកូនដំបូង។ លើសពីនេះ ស្ត្រីវ័យក្មេងចំនួន ២% គឺមានបទពិសោធន៍ពីការរលូតកូន។

ទោះជាយ៉ាងណាក៏ដោយ មានការធ្លាក់ចុះដ៏គួរឱ្យកត់សម្គាល់ចំពោះប្រេវ៉ាឡង់នៃការមានផ្ទៃពោះក្នុងវ័យជំទង់ក្នុងចំណោមស្ត្រីវ័យក្មេងដែលមានអាយុ ១៥–១៩ឆ្នាំ តាំងពីឆ្នាំ ២០១៤មក។ ទិន្នន័យបង្ហាញថា ការធ្លាក់ចុះគឺពី ១២% មក ៩% នៃសមាមាត្រសរុប។ គួរឱ្យកត់សម្គាល់ផងដែរថា និន្នាការនេះផ្សាភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងកម្រិតខ្ពស់បំផុតនៃការសិក្សា ដូចដែលបានឃើញជាក់ស្តែងថា ស្ត្រីវ័យក្មេងចំនួន ៣៥%ដែលមិនមានការអប់រំគ្រប់គ្រាន់ មានបទពិសោធន៍ក្នុងការមានផ្ទៃពោះ ប៉ុន្តែទិន្នន័យនៃការមានផ្ទៃពោះចំពោះស្ត្រីវ័យក្មេងដែលមានការសិក្សានៅកម្រិតអនុវិទ្យាល័យ មានការធ្លាក់ចុះដល់៧%។ យោងទៅតាមរបកគំហើញនៃ CDHS ឆ្នាំ ២០២១/២០២២ ត្រូវបានគេសង្កេតឃើញថា មានភាពខុសគ្នាតិចតួចរវាងយេនឌ័រទាក់ទងទៅនឹងទំនោរនៃចំណង់ផ្លូវភេទមុនឈានចូលដល់អាយុ១៥ឆ្នាំ។ ប្រេវ៉ាឡង់នៃអាកប្បកិរិយាបែបនេះ កើតមានក្នុងចំណោមស្ត្រីគឺច្រើនជាងប្រហែល១% ខណៈពេលដែលតួលេខបង្ហាញថា បុរសដែលមានអាកប្បកិរិយាបែបនេះមានតិចជាង១% ។

### ៤.១.៥ ការធ្វើអន្តរាគមន៍របស់រាជរដ្ឋាភិបាលកម្ពុជាលើបញ្ហា អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង នាពេលកន្លងមក

ផ្អែកតាមការត្រួតពិនិត្យលើទិន្នន័យដែលមានស្រាប់ ខាងក្រោមនេះជាការធ្វើអន្តរាគមន៍មួយចំនួនរបស់រាជរដ្ឋាភិបាលកម្ពុជា និងអ្នកពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហាអាពាហ៍ពិពាហ៍នៅវ័យកុមារ អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធវ័យក្មេង៖

១) ក្នុងឆ្នាំ២០១៨ ក្រសួងកិច្ចការនារី បានប្រកាសផែនការសកម្មភាពខេត្ត ស្តីពីការបញ្ចប់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះក្នុងវ័យជំទង់ (ឆ្នាំ២០១៧-ឆ្នាំ២០២១) ក្នុងខេត្តរតនគិរី ដោយមានការគាំទ្រពីអង្គការយូនីសេហ្វកម្ពុជា។ ផែនការសកម្មភាព ផ្តោតលើការបង្កើនអន្តរាគមន៍ បង្ការ និងឆ្លើយតបលើអាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះក្នុងចំណោមជនជាតិភាគតិច ព្រមទាំងមានបំណងធ្វើឱ្យការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការពហុវិស័យមានភាពប្រសើរឡើង ហើយក៏បានបង្កើតជាប្រព័ន្ធសម្រាប់ការប្រមូលទិន្នន័យ ការត្រួតពិនិត្យ និងការវាយតម្លៃផងដែរ។ ផែនការសកម្មភាពមានបំណងចង់សម្រេចឱ្យបានយ៉ាងហោចណាស់៣០% នៃយុវវ័យក្នុងខេត្ត(អាយុ១០-១៩ឆ្នាំ) និងយុវជន (អាយុពី ១៥ ទៅ ៣៥ ឆ្នាំ)។[12]

២) ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ (ឆ្នាំ២០១៧- ឆ្នាំ២០២១) បង្ហាញថា ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងត្រូវបានចាត់ទុកជាទម្រង់នៃអំពើហិង្សាលើកុមារ ជាពិសេសចំពោះក្មេងស្រី ដោយរួមបញ្ចូលទាំងគោលដៅពង្រឹងកម្មវិធីសហគមន៍ និងសមត្ថភាពរបស់មជ្ឈមណ្ឌលសាសនា ក្នុងការទប់ស្កាត់ កំណត់ និងឆ្លើយតបទៅនឹងស្ថានភាពរំលោភបំពានលើកុមារ និងរួមបញ្ចូលទាំងការរៀបអាពាហ៍ពិពាហ៍នៅវ័យកុមារផងដែរ។[13]

៣) អាពាហ៍ពិពាហ៍នៅវ័យក្មេង ត្រូវបានលើកឡើងថា ជាឧបសគ្គដ៏ធំក្នុងការលើកកម្ពស់ការអប់រំរបស់ក្មេងស្រីក្នុងយុទ្ធសាស្ត្រនារីរតនៈទី៤ (ឆ្នាំ២០១៤-ឆ្នាំ២០១៨)[14] ដែលជាផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំសម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងភាពងង់អាចរបស់ស្ត្រីដែលដឹកនាំដោយក្រសួងកិច្ចការនារី។ បញ្ហានេះក៏ត្រូវបានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ សម្រាប់ឆ្នាំ២០១៩-ឆ្នាំ២០២៣ ផងដែរ។[15]

ការត្រួតពិនិត្យមើលលើឯកសារដែលមានស្រាប់ និងការប្រឹក្សាជាមួយភាគីពាក់ព័ន្ធបានបង្ហាញថា ក្នុងការដោះស្រាយបញ្ហាអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមានយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិដែលគ្រប់ជ្រុងជ្រោយ ។

---

[12] ផែនការសកម្មភាពថ្នាក់ខេត្ត ស្តីពីការបញ្ចប់អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះក្នុងវ័យជំទង់ (២០១៧-២០២១) នៅខេត្តរតនគិរី
https://www.unicef.org/about/annualreport/files/Cambodia_2016_COAR.pdf

[13] ផែនការសកម្មភាពថ្នាក់ខេត្ត ស្តីពីការបញ្ចប់អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះក្នុងវ័យជំទង់ (២០១៧-២០២១) នៅខេត្តរតនគិរី
https://www.unicef.org/about/annualreport/files/Cambodia_2016_COAR.pdf

[14] យុទ្ធសាស្ត្រនារីរតនៈ IV (2014-2018),
http://www.kh.undp.org/content/dam/cambodia/docs/DemoGov/NearyRattanak4/Cambodian%20Gender%20Strategic%20Plan%20-%20Neary%20Rattanak%204_Eng.pdf

[15] https://sustainabledevelopment.un.org/content/documents/23603Cambodia_VNR_PublishingHLPF.pdf
https://sustainabledevelopment.un.org/content/documents/23603Cambodia_VNR_PublishingHLPF.pdf

## ៤.២ របកគំហើញដែលទទួលបានពីការស្ទង់មតិ និងការសម្ភាសន៍

### ៤.២.១ បុគ្គលិកលក្ខណៈសង្គម-ប្រជាសាស្ត្ររបស់អ្នកឆ្លើយតប

*តារាងទី ១៖ បុគ្គលិកលក្ខណៈសង្គម-ប្រជាសាស្ត្ររបស់អ្នកឆ្លើយតប*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | ចំនួន | % |
| **ខេត្តគោលដៅ** | | |
| ខេត្តសៀមរាប | ១៥០ | ១១.១១ |
| ខេត្តព្រះវិហារ | ១៥០ | ១១.១១ |
| ខេត្តបាត់ដំបង | ១៥០ | ១១.១១ |
| ខេត្តព្រៃវែង | ១៥០ | ១១.១១ |
| ខេត្តស្ទឹងត្រែង | ១៥០ | ១១.១១ |
| ខេត្តរតនគិរី | ១៥០ | ១១.១១ |
| ខេត្តតាកែវ | ១៥០ | ១១.១១ |
| ខេត្តកំពត | ១៥០ | ១១.១១ |
| ខេត្តព្រះសីហនុ | ១៥០ | ១១.១១ |
| **អាយុរបស់អ្នកឆ្លើយតប** | | |
| ២០ ឆ្នាំ | ៣៧១ | ២៧.៤៨ |
| ២១ ឆ្នាំ | ២០២ | ១៤.៩៦ |
| ២២ ឆ្នាំ | ១៨៨ | ១៣.៩៣ |
| ២៣ ឆ្នាំ | ២៩១ | ២១.៥៦ |
| ២៤ ឆ្នាំ | ២៩៨ | ២២.០៧ |
| **សំបុត្រកំណើត** | | |
| មាន | ១៣៤២ | ៩៩.៤១ |
| មិនមាន | ៨ | ០.៥៩ |
| **ជនជាតិ** | | |
| ខ្មែរ | ១២០១ | ៨៨.៩៦ |
| ចាម | ១១ | ០.៨១ |
| ការ៉ែត | ១ | ០.០៧ |
| ទំពួន | ២ | ០.១៥ |
| ព្រៅ | ៥៨ | ៤.៣ |
| លុន | ២ | ០.១៥ |
| ព្នង | ១ | ០.០៧ |
| ផ្សេងទៀត (គ្រឹង កួយ ឡាវ) | ៧៣ | ៥.៤១ |

| | | |
|---|---|---|
| **សាសនា** | | |
| ព្រះពុទ្ធ | ១២៣៣ | ៩១.៣៣ |
| គ្រឹស្ត | ៣០ | ២.២២ |
| អ៊ីស្លាម | ១១ | ០.៨១ |
| វិញ្ញាណនិយម | ៧៣ | ៥.៤១ |
| ផ្សេងទៀត | ៣ | ០.២២ |
| **ចំនួនបងប្អូនបង្កើតជាមធ្យម (មេដ្យាន)** | ៤.១៩ (៤) | |
| ចន្លោះ | ១-១៨ | |
| **ចំនួនបងប្អូនបង្កើត (គិតជាក្រុម)** | | |
| ១-៤ នាក់ | ៨៤៩ | ៦២.៨៩ |
| ៥-៩ នាក់ | ៤៨៤ | ៣៥.៨៥ |
| ១០ នាក់ឡើងទៅ | ១៧ | ១.២៦ |
| **កម្រិតអប់រំ** | | |
| អក្ខរកម្ម | ៤៩ | ៣.៦៣ |
| បឋមសិក្សា | ៣១១ | ២៣.០៤ |
| អនុវិទ្យាល័យ | ៤៣២ | ៣២ |
| វិទ្យាល័យ | ៣៨៦ | ២៨.៥៩ |
| បរិញ្ញាប័ត្រ | ១៧០ | ១២.៥៩ |
| ផ្សេងទៀត | ១ | ០.០៧ |
| **អ្នក និងគ្រួសាររបស់អ្នកមានប័ណ្ណសមធម៌** | | |
| មិនមាន | ១០៥២ | ៧៧.៩៣ |
| មិនមានទេ ប៉ុន្តែគ្រួសាររបស់ខ្ញុំមានជីវភាពក្រីក្រ | ១៥ | ១.១១ |
| មានប័ណ្ណសមធម៌កម្រិត ២ | ១០៤ | ៧.៧ |
| មានប័ណ្ណសមធម៌កម្រិត ១ | ១៧៩ | ១៣.២៦ |
| **ស្ថានភាពពិការភាព** | | |
| មាន | ៨ | ០.៥៩ |
| មិនមាន | ១៣៤២ | ៩៩.៤១ |
| **មុខរបរ** | | |
| សិស្ស | ១៦៦ | ១២.៣ |
| កសិករ | ៤៤៦ | ៣៣.០៤ |
| មេផ្ទះ | ១៦០ | ១១.៨៥ |

| | | |
|---|---|---|
| កម្មករក្នុងស្រុក | ២ | ០.១៥ |
| មានការងារ | ២៣៧ | ១៧.៥៦ |
| រកស៊ី | ២៣៥ | ១៧.៤១ |
| មិនមានការងារ | ៣០ | ២.២២ |
| បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល | ៩ | ០.៦៧ |
| មន្ត្រីរដ្ឋាភិបាល | ៣២ | ២.៣៧ |
| ផ្សេងទៀត (បុគ្គលិកធនាគារ កម្មកររោងចក្រ សាឡន។ល។) | ៣៣ | ២.៤៤ |
| **ស្ថានភាពអាពាហ៍ពិពាហ៍** | | |
| នៅលីវ | ៤៧៨ | ៣៥.៤១ |
| រៀបអាពាហ៍ពិពាហ៍រួចហើយ | ៨២៩ | ៦១.៤១ |
| រស់នៅជាមួយគ្នា ប៉ុន្តែពុំបានរៀបអាពាហ៍ពិពាហ៍ | ១៩ | ១.៤១ |
| ចែកផ្លូវគ្នា | ៤ | ០.៣ |
| លែងលះ | ២០ | ១.៤៨ |
| **ចំណូលប្រចាំខែ បើនៅលីវ** | | |
| ក្រោម ៥០$ | ៩២ | ១៩.២៥ |
| ៥១$ ដល់ ១០០$ | ៦៩ | ១៤.៤៤ |
| ១០១$ ដល់ ២០០$ | ១៣៩ | ២៩.០៨ |
| ២០១$ ដល់ ៣០០$ | ១២១ | ២៥.៣១ |
| ច្រើនជាង ៣០១$ | ៥៧ | ១១.៩២ |
| **ចំណូលប្រចាំខែបើរៀបអាពាហ៍ពិពាហ៍រួចហើយ រស់នៅជាមួយគ្នា ចែកផ្លូវគ្នា** | | |
| ក្រោម ៥០$ | ១០៧ | ១២.២៧ |
| ៥១$ ដល់ ១០០$ | ២០២ | ២៣.១៧ |
| ១០១$ ដល់ ២០០$ | ២៦៧ | ៣០.៦២ |
| ២០១$ ដល់ ៣០០$ | ១៨៧ | ២១.៤៤ |
| ច្រើនជាង ៣០១$ | ១០៩ | ១២.៥ |

ការស្រាវជ្រាវនេះត្រូវបានអនុវត្តក្នុងខេត្តចំនួន៩ ពិសេសខេត្តសៀមរាប ខេត្តរតនគិរី ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តបាត់ដំបង ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តព្រៃវែង និងខេត្តតាកែវ។ អ្នកឆ្លើយតបសរុបចំនួន ១៥០ នាក់ត្រូវបានជ្រើសរើសមកពីខេត្តនីមួយៗ។ ការស្ទង់មតិនេះត្រូវបានអនុវត្តលើអ្នកឆ្លើយតបជាស្ត្រីដែលមានអាយុចន្លោះពី ២០ ទៅ ២៤ ឆ្នាំ ដោយអនុលោមតាមកម្រិតថេរដែលបានកំណត់នៅក្នុងការសិក្សា ។ របកគំហើញនៃការស្ទង់មតិបង្ហាញថា ក្នុងចំណោមអ្នកឆ្លើយតប អ្នកដែលមានអាយុ ២០ឆ្នាំមានចំនួន ២៧% អ្នក

មានអាយុ ២១ឆ្នាំមានចំនួន ១៥% អ្នកមានអាយុ ២២ឆ្នាំ មានចំនួន ១៤% អ្នកមានអាយុ ២៣ឆ្នាំមានចំនួន ២២% ហើយ ២២% ទៀតជាអ្នកដែលមានអាយុ ២៤ ឆ្នាំ។

នៅពេលសួរសំណួរដែលទាក់ទងនឹងសំបុត្រកំណើតរបស់ពួកគេ អ្នកចូលរួម៩៩% បានបង្ហាញថាពួកគេមានសំបុត្រកំណើត។ របកគំហើញនៃការសិក្សានេះបង្ហាញថា អ្នកចូលរួមចំនួន៨៨.៩៦% បានបង្ហាញពីអត្តសញ្ញាណខ្លួនឯងថាជាជនជាតិខ្មែរ។ អ្នកឆ្លើយតបដែលនៅសេសសល់ជាជនជាតិផ្សេងៗ រួមមានជនជាតិចាម កាវ៉ែត ទំពួន ព្រៅ លុន ព្នង គ្រឹង កួយ និងឡាវ។

ការសិក្សាបង្ហាញថា ភាគច្រើនបំផុតនៃអ្នកចូលរួមចំនួន ៩១.៣៤% នៃអ្នកចូលរួមសរុបបញ្ជាក់ថាខ្លួនជាពុទ្ធសាសនិក។ក្រុមទីពីររួមមានអ្នកដែលមានជំនឿលើវិញ្ញាណនិយមមានចំនួន៥.៤១% ហើយ អ្នកកាន់សាសនាគ្រឹស្តជាក្រុមទីបី មានចំនួន ២.២២%។ អ្នកកាន់សាសនាអ៊ីស្លាមជាក្រុមទីបួនមានចំនួន ០.៨១%។

លទ្ធផលបង្ហាញថា ភាគច្រើននៃអ្នកចូលរួមចំនួន ៦៣% បានរាយការណ៍ថា មានបងប្អូនបង្កើតចាប់ពី ១ ដល់៤ នាក់នៅក្នុងគ្រួសាររបស់ពួកគេ។ លើសពីនេះ អ្នកឆ្លើយតបចំនួន ៣៦% បានរាយការណ៍ថា មានបងប្អូនបង្កើតពី៥ ដល់ ៩នាក់ ខណៈដែលអ្នកឆ្លើយតបចំនួន១% ទៀតរាយការណ៍ថា មានបងប្អូនបង្កើត១០ នាក់នៅក្នុងគ្រួសាររបស់ពួកគេ។

អ្នកឆ្លើយតបបានបង្ហាញពីកម្រិតអប់រំខុសៗគ្នា ដោយកម្រិតវប្បធម៌ខ្ពស់បំផុតគឺនៅអនុវិទ្យាល័យដែលមានចំនួន៣២% ។ លើសពីនេះទៅទៀត អ្នកឆ្លើយតបចំនួន ២៨.៥៩% បានរាយការណ៍ថា បានបញ្ចប់វិទ្យាល័យ ខណៈដែល ២៣.១២% ទៀតបានពិពណ៌នាថា ខ្លួនបានទទួលការអប់រំនៅកម្រិតបឋមសិក្សា។ ក្នុងចំណោមអ្នកចូលរួមសរុបមានចំនួន ៣.៦៣% អាចត្រូវបានចាត់ទុកថាជាអនក្ខរជន។

អ្នកចូលរួមភាគច្រើនមិនមានប័ណ្ណសមធម៌ទេ។ យ៉ាងណាមិញ អ្នកចូលរួមចំនួន ១៣.២៦% មានប័ណ្ណសមធម៌កម្រិត១ ហើយ៧.៧% ទៀតមានប័ណ្ណសមធម៌កម្រិត២ ។ លើសពីទៅទៀតនេះ អ្នកចូលរួមមួយចំនួនតូចចំនួន១.១% មិនមានប័ណ្ណសមធម៌ឡើយ ក៏ប៉ុន្តែពួកគេរស់នៅក្នុងគ្រួសារដែលជួបប្រទះភាពក្រីក្រខ្លាំង។ លទ្ធផលស្ទង់មតិបង្ហាញថា អ្នកចូលរួមត្រឹមតែ ១% ប៉ុណ្ណោះដែលមានពិការភាព។

ទិន្នន័យបង្ហាញថា អ្នកឆ្លើយតបចំនួន ៣៣.០៤% បញ្ជាក់ថាពួកគេជាកសិករ ខណៈដែល ១៧.៥៦% ទៀតបានរាយការណ៍ថា ពួកគេជានិយោជិក។ លើសពីនេះទៅទៀត អ្នកឆ្លើយតបចំនួន ១៧.៤១% បញ្ជាក់ថាពួកគេជាអ្នកធ្វើអាជីវកម្ម ១១.៨៥% ជាស្ត្រីមេផ្ទះ និង ១២.៣% ជាសិស្ស។ អ្នកឆ្លើយតបដែលនៅសេសសល់បានបញ្ជាក់ថាជាបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាល ឬអ្នកធ្វើការនៅក្នុងស្រុក។ លើសពីនេះទៅទៀត ជាការគួរឱ្យកត់សម្គាល់ដែរ អ្នកឆ្លើយតបចំនួន ២.២២% ដែលបានចូលរួមក្នុងការសិក្សា កំពុងជួបប្រទះភាពអត់ការងារធ្វើ។

លទ្ធផលនៃការស្ទង់មតិបង្ហាញថា អ្នកចូលរួមភាគច្រើនចំនួន ៦១.៤១% បានរាយការណ៍ថាពួកគេបានរៀបអាពាហ៍ពិពាហ៍រួច។ ផ្ទុយទៅវិញ អ្នកឆ្លើយតបចំនួន៣៥.៤១% បញ្ជាក់ថាពួកគេនៅលីវ ១.៤៨% បានលែងលះ០.៣% បានចែកផ្លូវគ្នា និង១.៤% ជាអ្នករស់នៅជាមួយគ្នាដោយមិនបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់។

អ្នកចូលរួមភាគច្រើនបំផុត (២៩.៨%) បានរាយការណ៍ថាមានប្រាក់ចំណូលប្រចាំខែចាប់ពី $១០១ ដល់$២០០ ។ ការស្ទង់មតិបានកត់សម្គាល់ថា អ្នកចូលរួមចំនួន ២៥.៣១% បានរាយការណ៍ថារកប្រាក់ចំណូលប្រចាំខែបានចាប់ពី $២០១ ដល់ $៣០០ ។ ផ្ទុយទៅវិញ មានអ្នកចូលរួមភាគតិចត្រឹមតែ ១១.៩២% ប៉ុណ្ណោះបង្ហាញថារកចំណូលបានច្រើនជាង$៣០១ ក្នុងមួយខែ។ ប៉ុន្តែ គួរឱ្យកត់សម្គាល់ដែរថាអ្នកចូលរួមចំនួន ១៤.៤៤% បានរាយការណ៍ថាមានប្រាក់ចំណូលប្រចាំខែចាប់ពី $៥១ដល់ $១០០ ហើយ១៩.២៥% ទៀតបង្ហាញថារកចំណូលបានតិចជាង $៥០ ក្នុងមួយខែ។ មានន័យថាអ្នកឆ្លើយតបប្រហែល ៣៤% មានប្រាក់ចំណូលប្រចាំខែបានតិចជាង $១០០។

ទាក់ទងនឹងអ្នកឆ្លើយតបដែលបានរៀបអាពាហ៍ពិពាហ៍រួច ឬរស់នៅជាមួយគ្នាជាប្តីប្រពន្ធ បង្ហាញឱ្យឃើញថា អ្នកឆ្លើយតបចំនួន ៣០.៦២% បានរាយការណ៍ថាអាចរកចំណូលបានពីចន្លោះ $១០១ ដល់ $២០០ មាន ២១.៤៤% បានរាយការណ៍ថារកចំណូលបានពីចន្លោះ $២០១ ដល់ $៣០០ និង១២.៥% ទៀតបានរាយការណ៍អាចថារកចំណូលបានច្រើនជាង $៣០១។ យ៉ាងណាមិញ អ្នកចូលរួមភាគច្រើនចំនួន ៣៥.៤៤% បានរាយការណ៍ថាមានប្រាក់ចំណូលប្រចាំខែតិចជាង $១០០។

## ៤.២.២ ផ្នត់គំនិត និងចំណេះដឹងអំពីអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង

*តារាងទី 2៖ យោងតាមគំនិតរបស់អ្នក ក្មេងស្រីអាយុក្រោម ១៨ ឆ្នាំបានរៀបអាពាហ៍ពិពាហ៍នៅក្នុងសហគមន៍របស់អ្នក*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | % |
| យោងតាមគំនិតរបស់អ្នក ក្មេងស្រីអាយុក្រោម ១៨ ឆ្នាំបានរៀបអាពាហ៍ពិពាហ៍នៅក្នុងសហគមន៍របស់អ្នក | | |
| ទាំងអស់ | ៣៩ | ២.៨៩ |
| ភាគច្រើន | ៤៣៨ | ៣២.៤៤ |
| ខ្លះៗ | ៣៧៥ | ២៧.៧៨ |
| ភាគតិច | ២៩៥ | ២១.៨៥ |
| មិនមាន | ១៣២ | ៩.៧៨ |
| មិនច្បាស់- មិនដឹង | ៧១ | ៥.២៦ |

តារាងខាងលើបង្ហាញពីការយល់ឃើញទូទៅទាក់ទងនឹងស្ថានភាពអាពាហ៍ពិពាហ៍របស់ក្មេងស្រីនៅទូទាំងសហគមន៍របស់ពួកគេ។ យោងតាមអ្នកឆ្លើយតបចំនួន ៣២.៤៤% ស្ត្រីដែលមានអាយុក្រោម ១៨ ឆ្នាំភាគច្រើនត្រូវបានរកឃើញថា បានរៀបអាពាហ៍ពិពាហ៍នៅក្នុងសហគមន៍របស់ពួកគេ។ យោងតាមការស្ទង់មតិស្ត្រីដែលមានអាយុក្រោម ១៨ ឆ្នាំចំនួន ២៧.៧៨% ត្រូវបានរាយការណ៍ថា បានរៀបអាពាហ៍ពិពាហ៍នៅក្នុងសហគមន៍របស់ពួកគេ។ យ៉ាងណាមិញ គួរឱ្យកត់សម្គាល់ថា អ្នកឆ្លើយតបចំនួន ៩.៧៨% បានរាយការណ៍ថានៅក្នុងសហគមន៍របស់ពួកគេ មិនមានក្មេងស្រីដែលរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងឡើយ។

*តារាងទី 3៖ យោងតាមគំនិតរបស់អ្នក ក្មេងប្រុសអាយុក្រោម ១៨ ឆ្នាំបានរៀបការនៅក្នុងសហគមន៍របស់អ្នក*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | % |
| យោងតាមគំនិតរបស់អ្នក ក្មេងប្រុសអាយុក្រោម ១៨ ឆ្នាំបានរៀបអាពាហ៍ពិពាហ៍នៅក្នុងសហគមន៍របស់អ្នក | | |
| ទាំងអស់ | ២៤ | ១.៧៨ |
| ភាគច្រើន | ២០៨ | ១៥.៤១ |
| ខ្លះៗ | ៣១៤ | ២៣.២៦ |
| ភាគតិច | ២៧០ | ២០ |
| មិនមាន | ៤៤៦ | ៣៣.០៤ |
| មិនច្បាស់- មិនដឹង | ៨៨ | ៦.៥២ |

តារាងខាងលើបង្ហាញពីផ្នត់គំនិតផ្សេងៗ គ្នាទាក់ទងនឹងប្រេវ៉ាឡង់ នៃការរៀបអាពាហ៍ពិពាហ៍របស់ក្មេងប្រុសទៅតាមក្រុមរៀងៗខ្លួន។ តាមលទ្ធផលនៃការស្ទង់មតិអ្នកចូលរួម ១.៧៨% បានបញ្ជាក់ថា ក្នុងសហគមន៍របស់ខ្លួនមានការអនុវត្តនូវការរៀបអាពាហ៍ពិពាហ៍ឱ្យក្មេងប្រុសទាំងអស់ដែលមានអាយុក្រោម ១៨ ឆ្នាំ។

*តារាងទី 4៖ ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងស្រីមុនអាយុ ១៥ ឆ្នាំនៅក្នុងសហគមន៍របស់អ្នកចាប់តាំងពីឆ្នាំមុន*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | % |
| តាមគំនិតរបស់អ្នក ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងស្រីមុនអាយុ ១៥ ឆ្នាំនៅក្នុងសហគមន៍របស់អ្នកចាប់តាំងពីឆ្នាំមុន | | |
| កើនឡើង | ៦៣៧ | ៤៧.១៩ |
| ថយចុះ | ១៦៥ | ១២.២២ |
| នៅដដែល | ១៤៨ | ១០.៩៦ |
| មិនច្បាស់- មិនដឹង | ៤០០ | ២៩.៦៣ |

ការសិក្សាស្រាវជ្រាវបានបង្ហាញថា អ្នកចូលរួមចំនួន៤៧.១៩% បានទទួលស្គាល់ថាប្រេវ៉ាឡង់នៃការរៀបអាពាហ៍ពិពាហ៍ដែលពាក់ព័ន្ធនឹងក្មេងស្រីអាយុក្រោម ១៥ ឆ្នាំមានការកើនឡើង បើប្រៀបធៀបទៅនឹងឆ្នាំមុន។ ផ្ទុយទៅវិញ អ្នកចូលរួមសរុបចំនួន ១២.២២% បានបញ្ជាក់ថា បញ្ហានេះមានការថយចុះ ហើយ ១០.៩៦% ទៀតបាននិយាយថាវាមិនមានការផ្លាស់ប្តូរឡើយ។ គួរឱ្យកត់សម្គាល់ដែរថា អ្នកចូលរួមភាគច្រើនចំនួន ២៩.៦៣% បានបង្ហាញពីភាពមិនច្បាស់លាស់ទាក់ទងទៅនឹងស្ថានភាពបច្ចុប្បន្ន។ ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងស្រីមុនអាយុ ១៥ ឆ្នាំគឺជាប្រធានបទដែលមានការជជែកដេញដោលដោយមានផ្នត់គំនិតខុសៗគ្នាជាច្រើន។ យ៉ាងណាមិញអ្នកឆ្លើយតបភាគច្រើនបង្ហាញថាបញ្ហានេះមានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងសហគមន៍របស់ពួកគេ។

*តារាង ៥៖ ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងប្រុសមុនអាយុ ១៥ ឆ្នាំនៅក្នុងសហគមន៍របស់អ្នកចាប់តាំងពីឆ្នាំមុន*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | % |
| តាមគំនិតរបស់អ្នក ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងប្រុសមុនអាយុ ១៥ ឆ្នាំនៅក្នុងសហគមន៍របស់អ្នកចាប់តាំងពីឆ្នាំមុន | | |
| កើនឡើង | ៦៤៥ | ៤៧.៧៨ |
| ថយចុះ | ៨៨ | ៦.៥២ |
| នៅដដែល | ១៨២ | ១៣.៤៨ |
| មិនច្បាស់- មិនដឹង | ៤៣៥ | ៣២.២២ |

គួរឱ្យកត់សម្គាល់ថា អ្នកឆ្លើយតបចំនួន ៤៧.៨% បានបង្ហាញថា បញ្ហាដែលទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងចំពោះក្មេងប្រុសមានការកើនឡើង បើប្រៀបធៀបទៅនឹងឆ្នាំមុន។ ផ្ទុយទៅវិញអ្នកឆ្លើយតបចំនួន៦.៥២% បានរាយការណ៍ថាមានការធ្លាក់ចុះ ខណៈដែល១៣.៤៨% ទៀតបញ្ជាក់ថា មិនមានការផ្លាស់ប្តូរនោះទេ។ គួរឱ្យគត់សម្គាល់ថា អ្នកឆ្លើយតបភាគច្រើនចំនួន៣២.២២% បានបង្ហាញពីភាពមិនច្បាស់លាស់ទាក់ទងនឹងប្រេវ៉ាឡង់នៃការអនុវត្តនេះ ។ ស្របពេលដែលមានផ្នត់គំនិតជាច្រើនទាក់ទិននឹងការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងប្រុសមុនអាយុ១៥ឆ្នាំ ចាប់តាំងពីឆ្នាំមុនមក មានអ្នកចូលរួមជាច្រើនបញ្ជាក់ថា ទម្លាប់នេះនៅតែបន្តរុញច្រានឱ្យកើតមានឡើងនៅក្នុងសហគមន៍របស់ពួកគេ។

*តារាង ៦៖ ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងស្រីមុនអាយុ ១៨ ឆ្នាំនៅក្នុងសហគមន៍របស់អ្នកចាប់តាំងពីឆ្នាំមុន*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | % |
| តាមគំនិតរបស់អ្នក ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងស្រីមុនអាយុ ១៨ ឆ្នាំនៅក្នុងសហគមន៍របស់អ្នកចាប់តាំងពីឆ្នាំមុន | | |
| កើនឡើង | ៦៩៨ | ៥១.៧ |
| ថយចុះ | ៣៥៦ | ២៦.៣៧ |
| នៅដដែល | ១៧៩ | ១៣.២៦ |
| មិនច្បាស់- មិនដឹង | ១១៧ | ៨.៦៧ |

តារាងនេះបានបង្ហាញពីផ្នត់គំនិតផ្សេងៗគ្នាអំពីការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងស្រីមុនអាយុ ១៨ ឆ្នាំ។ អ្នកឆ្លើយតបចំនួន ៥១.៧% បានបង្ហាញថា បានកើនឡើងតាំងតែពីឆ្នាំមុនមកម្ល៉េះ ហើយអ្នកឆ្លើយតបចំនួន ១៣.២៦% ទៀតបានបញ្ជាក់ថា មិនមានភាពផ្លាស់ប្តូរនោះទេ ហើយអ្នកឆ្លើយតបចំនួន ៨.៦៧% ទៀតមិនប្រាកដអំពីបញ្ហានេះឡើយ។ ផ្ទុយទៅវិញ អ្នកឆ្លើយតបចំនួន ២៦.៣៧% បានបង្ហាញថា មានការថយចុះតាំងពីឆ្នាំមុន។ បើទោះបីជាមានផ្នត់គំនិតជាច្រើនពាក់ព័ន្ធទៅនឹងការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងស្រីមុនអាយុ ១៨ឆ្នាំក៏ដោយ ក៏អ្នកឆ្លើយតបភាគច្រើនបានបញ្ជាក់ថា ការអនុវត្តបែបនេះនៅតែបន្តកើនឡើងនៅក្នុងសហគមន៍របស់ពួកគេ។

*តារាងទី ៧៖ ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងប្រុសមុនអាយុ ១៨ឆ្នាំនៅក្នុងសហគមន៍របស់អ្នកចាប់តាំងពីឆ្នាំមុន*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | ចំនួន | % |
| តាមគំនិតរបស់អ្នក ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងប្រុសមុនអាយុ ១៨ ឆ្នាំនៅក្នុងសហគមន៍របស់អ្នកចាប់តាំងពីឆ្នាំមុន | | |
| កើនឡើង | ៧៣៤ | ៥៤.៣៧ |
| ថយចុះ | ២២២ | ១៦.៤៤ |
| នៅដដែល | ២១៦ | ១៦ |
| មិនច្បាស់- មិនដឹង | ១៧៨ | ១៣.១៩ |

តារាងខាងលើបង្ហាញពីផ្នត់គំនិតផ្សេងៗគ្នាលើការអនុវត្តការរៀបអាពាហ៍ពិពាហ៍ ក្មេងប្រុសមុនអាយុ ១៨ឆ្នាំ។ ក្នុងចំណោមអ្នកឆ្លើយតបទាំងអស់ មានអ្នកឆ្លើយតបចំនួន ៥៤.៣៧% បានបង្ហាញថា ការអនុវត្តនេះ មានការកើនឡើងគួរឱ្យកត់សម្គាល់បើធៀបទៅនឹងឆ្នាំមុន។ លើសពីនេះទៅទៀតអ្នកឆ្លើយតបចំនួន១៦% បានបញ្ជាក់ថាប្រេវ៉ាឡង់នៃការរៀបអាពាហ៍ពិពាហ៍បែបនេះនៅតែមិនមានការផ្លាស់ប្តូរ ចំណែកអ្នកឆ្លើយតបចំនួន ១៣.៩% ទៀតបានបង្ហាញពីភាពមិនច្បាស់លាស់លើបញ្ហានេះ។ ផ្ទុយទៅវិញអ្នកចូលរួមចំនួន ១៦.៤៤% បានបង្ហាញថា បញ្ហានេះមានការថយចុះ បើធៀបទៅនឹងឆ្នាំមុន។ ស្របពេលដែលមានផ្នត់គំនិតជាច្រើនទាក់ទងនឹងការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្មេងប្រុសមុនអាយុ ១៨ ឆ្នាំ ទស្សនៈទូទៅរបស់អ្នកឆ្លើយតបភាគច្រើនបង្ហាញថាបញ្ហានេះមានការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងសហគមន៍របស់ពួកគេ។

*តារាងទី ៨៖ ការរៀបអាពាហ៍ពិពាហ៍ដែលផ្តល់ការការពារដល់ក្មេងស្រី*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | ចំនួន | % |
| ការរៀបអាពាហ៍ពិពាហ៍ដែលផ្តល់ការការពារដល់ក្មេងស្រី | | |
| យល់ស្រប | ៦៧៦ | ៥០.០៧ |
| មិនយល់ស្រប | ៥៩៦ | ៤៤.១៥ |
| មិនច្បាស់- មិនដឹង | ៧៨ | ៥.៧៨ |

តារាងខាងលើបង្ហាញពីផ្នត់គំនិតផ្សេងៗ គ្នាអំពីការការពារនានា ដែលក្មេងស្រីអាចទទួលបានពីអាពាហ៍ពិពាហ៍ដោយក្នុងនោះមានអ្នកចូលរួមចំនួន ៥០.០៧% បានយល់ស្របជាមួយនឹងផ្នត់គំនិតនេះ។ ផ្ទុយទៅវិញ អ្នកឆ្លើយតបចំនួន ៤៤.១៥% បានសម្តែងការមិនយល់ស្របនឹងការអះអាងខាងលើ ហើយភាគរយតិចជាងគេនៃអ្នកឆ្លើយតបចំនួន ៥.៧៨% បានបង្ហាញពីភាពមិនច្បាស់លាស់ទាក់ទងនឹងចំណុចនេះ។

*តារាងទី ៩៖ បម្រែបម្រួលរូបរាងកាយគឺជាសញ្ញាបង្ហាញថា ក្មេងស្រីបានត្រៀមខ្លួនរួចរាល់សម្រាប់ការរៀបអាពាហ៍ពិពាហ៍*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | ភាគរយ | % |
| បម្រែបម្រួលរូបរាងកាយគឺជាសញ្ញាបង្ហាញថា ក្មេងស្រីបានត្រៀមខ្លួនរួចរាល់សម្រាប់ការរៀបអាពាហ៍ពិពាហ៍ | | |
| យល់ស្រប | ៦៤៤ | ៤៧.៧ |
| មិនយល់ស្រប | ៦៦៣ | ៤៩.១១ |
| មិនច្បាស់- មិនដឹង | ៤៣ | ៣.១៩ |

ទាក់ទងនឹងផ្នត់គំនិតលើបម្រែបម្រួលរូបរាងកាយ និងទំនាក់ទំនងរបស់វាជាមួយនឹងការរៀបអាពាហ៍ពិពាហ៍ បានឱ្យឃើញថាមានតែអ្នកឆ្លើយតបចំនួន ៤៧.៧% ប៉ុណ្ណោះដែលជឿជាក់ថាការផ្លាស់ប្តូររូបរាងរាងកាយរបស់មនុស្សស្រីម្នាក់ បង្ហាញថាគាត់បានត្រៀមខ្លួនរួចរាល់សម្រាប់ការរៀបអាពាហ៍ពិពាហ៍។ អ្នកចូលរួមប្រហែល ៣.១៩% បង្ហាញពីភាពមិនច្បាស់លាស់លើបញ្ហានេះ។ ផ្ទុយទៅវិញ អ្នកចូលរួមភាគច្រើនចំនួន ៤៩.១១% មិនយល់ស្របជាមួយនឹងការអះអាងខាងលើ។

*តារាងទី 10៖ ក្មេងស្រីអាយុក្រោម ១៨ ឆ្នាំមានកូនច្រើនជាងក្មេងស្រីដែលមានអាយុលើសពី ១៨ ឆ្នាំ។*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | ភាគរយ | % |
| ក្មេងស្រីអាយុក្រោម ១៨ ឆ្នាំមានកូនច្រើនជាងក្មេងស្រីដែលមានអាយុលើសពី ១៨ឆ្នាំ | | |
| យល់ស្រប | ៧៣៣ | ៥៤.៣ |
| មិនយល់ស្រប | ៥៣១ | ៣៩.៣៣ |
| មិនច្បាស់- មិនដឹង | ៨៥ | ៦.៣ |
| បដិសេធមិនឆ្លើយ | ១ | ០.០៧ |

ទិន្នន័យនៅក្នុងតារាងនេះបង្ហាញថា អ្នកចូលរួមភាគច្រើនចំនួន ៥៤.៣% ជឿជាក់ថាស្ត្រីដែលមានអាយុក្រោម ១៨ ឆ្នាំមានអត្រាមានកូន ខ្ពស់ជាងស្ត្រីដែលមានអាយុខ្ពង់ ១៨ឆ្នាំ។ ផ្ទុយទៅវិញ អ្នកចូលរួមភាគច្រើនចំនួន ៣៩.៣៣% បានសម្តែងការមិនយល់ស្របជាមួយនឹងផ្នត់គំនិតទូទៅនេះ ខណៈដែលអ្នកចូលរួមភាគតិចចំនួន ៦.៣% មិនមានភាពច្បាស់លាស់។ លើសពីនេះទៅទៀត អ្នកចូលរួមចំនួន ០.០៧% បានបដិសេធមិនបង្ហាញគំនិតរបស់ពួកគេលើបញ្ហានេះ។

*តារាងទី 11៖ ការរៀបអាពាហ៍ពិពាហ៍ជាមួយក្មេងស្រីអាយុក្រោម ១៨ ឆ្នាំធានាបាននូវភាពបរិសុទ្ធ (ព្រហ្មចារីយ៍) នៅថ្ងៃរៀបមង្គលការ*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | % |
| ការរៀបអាពាហ៍ពិពាហ៍ជាមួយក្មេងស្រីអាយុក្រោម១៨ ឆ្នាំធានាបាននូវភាពបរិសុទ្ធ (ព្រហ្មចារីយ៍)នៅថ្ងៃរៀបមង្គលការ | | |
| យល់ស្រប | ៥៤០ | ៤០.០ |
| មិនយល់ស្រប | ៦៥៨ | ៤៨.៧៤ |
| មិនច្បាស់- មិនដឹង | ១៥០ | ១១.១១ |
| បដិសេធមិនឆ្លើយ | ២ | ០.១៥ |

យោងតាមទិន្នន័យដែលមានបង្ហាញនៅក្នុងតារាង បានបង្ហាញថាអ្នកចូលរួមចំនួន ៤០% ជឿជាក់ថាការរៀបអាពាហ៍ពិពាហ៍ជាមួយក្មេងស្រីដែលមានអាយុក្រោម ១៨ ឆ្នាំធានាបាននូវការរក្សាភាពបរិសុទ្ធ ពោលគឺព្រហ្មចារីយ៍នៅថ្ងៃរៀបមង្គលការ។ ផ្ទុយទៅវិញ អ្នកចូលរួមភាគច្រើនចំនួន ៤៨.៧៤% បានសម្តែងការមិនយល់ស្របជាមួយនឹងផ្នត់គំនិតនេះ។ អ្នកចូលរួម ១១.១១% បានបង្ហាញភាពមិនច្បាស់លាស់អំពីបញ្ហានេះ។

*តារាងទី 12៖ ការរៀបអាពាហ៍ពិពាហ៍ជាមួយក្មេងអាយុក្រោម ១៨ ឆ្នាំ ជួនកាលអាចជាមធ្យោបាយរកប្រាក់យកទៅសងបំណុល*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | % |
| **ការរៀបអាពាហ៍ពិពាហ៍ជាមួយក្មេងអាយុក្រោម ១៨ ឆ្នាំ ជួនកាលអាចជាមធ្យោបាយរកប្រាក់យកទៅសងបំណុល** | | |
| យល់ស្រប | ៣១៩ | ២៣.៦៣ |
| មិនយល់ស្រប | ៩៨៧ | ៧៣.១១ |
| មិនច្បាស់- មិនដឹង | ៤១ | ៣.០៤ |
| បដិសេធមិនឆ្លើយ | ៣ | ០.២២ |

អ្នកចូលរួមចំនួន ២៣.៦៣% បង្ហាញពីទំនាក់ទំនងនៃការរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលមានអាយុក្រោម ១៨ ឆ្នាំ ជាមួយនឹងការសងបំណុលថា ជួនកាល ជាវិធីសាស្ត្រមួយដើម្បីរកប្រាក់ទៅទូទាត់សងបំណុល។ ផ្ទុយទៅវិញ អ្នកចូលរួមភាគច្រើនចំនួន ៧៣.១១% បានសម្តែងការមិនយល់ស្របជាមួយនឹងការអះអាងខាងលើនេះ។ ក្នុងចំណោមអ្នកចូលរួមដែលបានស្ទង់មតិ មានចំនួន ៣.០៤% បង្ហាញពីភាពមិនច្បាស់លាស់ ខណៈមួយភាគតូចទៀតដែលមានចំនួន ០.២២% បានបដិសេធមិនផ្តល់គំនិតលើបញ្ហានេះ។

*តារាងទី 13៖ នៅក្នុងសហគមន៍របស់អ្នកក៏មានទម្លាប់ជូនថ្លៃបណ្ណាការដែរ*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | % |
| នៅក្នុងសហគមន៍របស់អ្នកក៏មានទម្លាប់ជូនថ្លៃ**បណ្ណា**ការដែរ | | |
| មាន | ១២៣២ | ៩១.២៦ |
| មិនមាន | ១១៧ | ៨.៦៧ |
| មិនច្បាស់- មិនដឹង | ១ | ០.០៧ |
| បដិសេដមិនឆ្លើយ | ០ | ០ |

ទិន្នន័យខាងលើបង្ហាញថា ជាទូទៅក្នុងសង្គមនៅតែមានទម្លាប់ជូនថ្លៃបណ្ណាការដដែល។ អ្នកឆ្លើយតបប្រមាណជា ៩១.២៦% បានបញ្ជាក់ថាការផ្តល់ជូនថ្លៃបណ្ណាការនៅតែមាន ខណៈដែលអ្នកឆ្លើបតបចំនួន ៨.៦៧% ទៀតបដិសេដថាមិនមាន។ អ្នកឆ្លើយតបភាគតិចចំនួន ០.០៧% បានបង្ហាញពីភាពមិនច្បាស់លាស់លើការអនុវត្តមួយនេះ។

*តារាងទី 14៖ ថ្លៃបណ្ណាការនឹងមានតម្លៃទាប នៅពេលកុមារកាន់តែមានអាយុក្មេង និងមានការអប់រំតិចតួច*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | % |
| **ថ្លៃបណ្ណាការ**នឹងមានតម្លៃទាប នៅពេលកុមារកាន់តែមានអាយុក្មេង និងមានការអប់រំតិចតួច | | |
| យល់ស្រប | ៤៧២ | ៣៤.៩៦ |
| មិនយល់ស្រប | ៨៣១ | ៦១.៥៦ |
| មិនច្បាស់- មិនដឹង | ៤៧ | ៣.៤៨ |
| បដិសេដមិនឆ្លើយ | ០ | ០ |

ទិន្នន័យនៅក្នុងតារាងបានបង្ហាញថាអ្នកចូលរួមភាគច្រើន (៦១.៥៦%) បានសម្តែងការមិនយល់ស្រប ជាមួយនឹងគំនិតដែលថាថ្លៃបណ្ណាការមានការថយចុះនៅពេលដែលកុមារមានអាយុក្មេង និងកម្រិតអប់រំទាប។ យ៉ាងណាមិញ អ្នកចូលរួមសរុបចំនួន ៣៤.៩៦% បានសម្តែងការយល់ស្របជាមួយនឹងការអះអាងខាងលើ។ អ្នកចូលរួមប្រហែល ៣.៤៨% បានបង្ហាញពីភាពមិនច្បាស់លាស់លើបញ្ហានេះ។

*តារាងទី 15៖ ក្មេងស្រីដែលមានអាយុច្រើនជាង ១៨ ឆ្នាំហើយមិនទាន់រៀបអាពាហ៍ពិពាហ៍គឺជាបន្ទុករបស់គ្រួសារ*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | % |
| **ក្មេងស្រីដែលមានអាយុច្រើនជាង ១៨ ឆ្នាំហើយមិនទាន់រៀបអាពាហ៍ពិពាហ៍ គឺជាបន្ទុករបស់គ្រួសារ** | | |
| យល់ស្រប | ៤៧៥ | ៣៥.១៩ |
| មិនយល់ស្រប | ៨៥២ | ៦៣.១១ |
| មិនច្បាស់- មិនដឹង | ២២ | ១.៦៣ |
| បដិសេធមិនឆ្លើយ | ១ | ០.០៧ |

នៅពេលសាកសួរអំពីការចំណាយរបស់ក្មេងស្រីដែលមានអាយុច្រើនជាង ១៨ ឆ្នាំហើយ តែមិនទាន់បានរៀបអាពាហ៍ពិពាហ៍ដែលអាចជាបន្ទុកដល់គ្រួសារ អ្នកឆ្លើយតបភាគច្រើនបានបង្ហាញពីការមិនយល់ស្របលើការអះអាងនេះ។ ផ្ទុយទៅវិញ គួរឱ្យកត់សម្គាល់ថាអ្នកឆ្លើយតបភាគច្រើនចំនួន ៣៥.១៩% មានជំនឿបែបនេះ។ ក្នុងចំណោមអ្នកចូលរួមទាំងអស់ មានចំនួន ១.៦៣% បង្ហាញពីភាពមិនច្បាស់លាស់ ខណៈមួយភាគតូចទៀតដែលមានចំនួន ០.០៧% បានបដិសេធមិនផ្តល់គំនិតលើបញ្ហានេះ។

*តារាងទី 16៖ ការរៀបអាពាហ៍ពិពាហ៍មុនអាយុ ១៨ ឆ្នាំគឺជាការតម្រូវដោយសាសនា ឬប្រពៃណី*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | % |
| **ការរៀបអាពាហ៍ពិពាហ៍មុនអាយុ ១៨ ឆ្នាំគឺជាការតម្រូវដោយសាសនា ឬប្រពៃណី** | | |
| យល់ស្រប | ២៨៧ | ២១.២៦ |
| មិនយល់ស្រប | ១០៣៩ | ៧៦.៩៦ |
| មិនច្បាស់- មិនដឹង | ២៤ | ១.៧៨ |

ទិន្នន័យដែលបង្ហាញក្នុងតារាងនេះ បញ្ជាក់ថាអ្នកឆ្លើយតបភាគច្រើនចំនួន ៧៦.៩៦% បានរាយការណ៍ថាកាតព្វកិច្ចសាសនា ឬប្រពៃណីលែងទាមទារឱ្យរៀបអាពាហ៍ពិពាហ៍មុនអាយុ ១៨ ឆ្នាំហើយ។ យ៉ាងណាមិញ គួរឱ្យកត់សម្គាល់ដែរថា អ្នកឆ្លើយតបចំនួន ២១.២៦% បន្តមានជំនឿប្រកាន់ខ្ជាប់ទំនៀមទម្លាប់ សាសនា ឬប្រពៃណី ដែលចាំបាច់ត្រូវឱ្យកូនរៀបអាពាហ៍ពិពាហ៍មុនអាយុ ១៨ ឆ្នាំ។ អ្នកចូលរួមប្រហែល ១.៧៨% បានបង្ហាញពីភាពមិនច្បាស់លាស់ទាក់ទងនឹងបញ្ហានេះ។

*តារាងទី 17៖ ក្មេងស្រីវ័យជំទង់ភាគច្រើនចូលចិត្តរៀបអាពាហ៍ពិពាហ៍មុនអាយុ ១៨ ឆ្នាំ*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | % |
| **ក្មេងស្រីវ័យជំទង់ភាគច្រើនចូលចិត្តរៀបអាពាហ៍ពិពាហ៍មុនអាយុ ១៨ ឆ្នាំ** | | |
| យល់ស្រប | ៦០៦ | ៤៤.៨៩ |
| មិនយល់ស្រប | ៦៩៣ | ៥១.៣៣ |
| មិនច្បាស់- មិនដឹង | ៤៩ | ៣.៦៣ |
| បដិសេដមិនឆ្លើយ | ២ | ០.១៥ |

អ្នកចូលរួមមានផ្នត់គំនិតជាច្រើនចំពោះបញ្ហាដែលថាក្មេងស្រីវ័យជំទង់ភាគច្រើនចូលចិត្តរៀបអាពាហ៍ពិពាហ៍មុនអាយុ ១៨ឆ្នាំ។ អ្នកចូលរួមសរុបចំនួន ៥១.៣៣% បានសម្តែងការមិនយល់ស្របចំពោះការអះអាងនេះ។ ផ្ទុយទៅវិញ អ្នកឆ្លើយតបភាគច្រើន ៤៤.៨៩% មានភាពជឿជាក់ថាក្មេងស្រីវ័យជំទង់ភាគច្រើនចង់រៀបអាពាហ៍ពិពាហ៍មុនអាយុ ១៨ ឆ្នាំ។ អ្នកចូលរួមមួយចំនួនតូចចំនួន ០.១៥% បដិសេដមិនបញ្ចេញមតិហើយ ៣.៦៣% ទៀតមិនមានភាពច្បាស់លាស់លើបញ្ហានេះ។

## ៤.២.៣ អត្រាប្រេវ៉ាឡង់នៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង

លទ្ធផលនៃការសិក្សានេះបង្ហាញថា អ្នកឆ្លើយតបភាគតិចចំនួន ០.៥០% បានរៀបអាពាហ៍ពិពាហ៍មុនអាយុ ១៥ ឆ្នាំ។ លើសពីនេះទៅទៀត ជាការសំខាន់ណាស់ដែលត្រូវសង្កត់ធ្ងន់ថា អ្នកចូលរួមភាគច្រើនចំនួន ១៣.៩៣% និយាយថាពួកគេបានរៀបអាពាហ៍ពិពាហ៍ក្នុងចន្លោះអាយុចាប់ពី១៥ដល់១៨ ឆ្នាំ។ ភាគរយដ៏ច្រើននៃអ្នកឆ្លើយតបចំនួន ៥០.១៥% បានរៀបអាពាហ៍ពិពាហ៍នៅអាយុ ១៨ ឆ្នាំឬអាយុច្រើនជាងនេះ ស្របពេលដែលអ្នកដែលនៅលីវមាន ៣៥.៤០%។ ជាលទ្ធផល របកគំហើញរបស់ការសិក្សាបង្ហាញថា ស្ត្រីភាគច្រើនពោលគឺ ១៤.៤៤% បានរៀបអាពាហ៍ពិពាហ៍មុនអាយុ ១៨ ឆ្នាំ។

*តារាងទី 18:អត្រាប្រេវ៉ាឡង់នៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង មុនអាយុ ១៥ឆ្នាំ និង ក្រោមអាយុ ១៨ឆ្នាំ*

| បុគ្គលិកលក្ខណៈ | សរុប (N=១៣៥០) | |
|---|---|---|
| | **ចំនួន** | **%** |
| អាយុមធ្យមដែលអាចរៀបអាពាហ៍ពិពាហ៍/រស់នៅជាមួយគ្នា (មេដ្យាន) (N=៨៧២) | ១៨.៩៩ (១៩) | |
| ចន្លោះ | ១១ - ២៦ ឆ្នាំ | |
| អាយុរៀបអាពាហ៍ពិពាហ៍/រស់នៅជាមួយគ្នា (N=១៣៥០) | | |
| < ១៥ ឆ្នាំ | ៧ | ០.៨០ |
| >=១៥ ឆ្នាំ <១៨ ឆ្នាំ | ១៨៨ | ២១.៥៦ |
| >= ១៨ ឆ្នាំ | ៦៧៧ | ៧៧.៦៤ |
| អាយុជាមធ្យមរបស់ប្តីគិតជាឆ្នាំនៅពេលនោះ (មេដ្យាន) (N=៨៧២) | ២២.៩៥ (២២) | |
| ចន្លោះ | ១២ - ៤៥ ឆ្នាំ | |

| | | |
|---|---|---|
| អាយុរបស់ស្វាមីនៅពេលរៀបអាពាហ៍ពិពាហ៍/រស់នៅជាមួយគ្នា (N= ១៣៥០) | | |
| < ១៥ ឆ្នាំ | ៣ | ០.៣៤ |
| >=១៥ ឆ្នាំ <១៨ ឆ្នាំ | ៤០ | ៤.៥៩ |
| >= ១៨ ឆ្នាំ | ៨២៩ | ៩៥.០៧ |
| បានចុះសំបុត្រអាពាហ៍ពិពាហ៍ (N=៨៧២) | | |
| បាទ/ចាស | ២៨៦ | ៣២.៨ |
| ទេ | ៥៨៤ | ៦៦.៩៧ |
| មិនច្បាស់- មិនដឹង | ២ | ០.២៣ |
| **រៀបអាពាហ៍ពិពាហ៍**ដោយក្តីស្រលាញ់ ឬចាស់ទុំផ្សំផ្គុំ (N=៨៧២) | | |
| រៀបអាពាហ៍ពិពាហ៍ដោយក្តីស្រលាញ់ | ៨១១ | ៩៣.០ |
| យល់ព្រមតាមចាស់ទុំផ្សំផ្គុំ | ៦១ | ៧.០ |
| អាយុជាមធ្យមនៃការមានផ្ទៃពោះ (មេដ្យាន) | ១៧.០៤ (១៩) | |
| ចន្លោះ | ១៤ - ២៤ ឆ្នាំ | |
| ក្រុមអាយុអ្នកដែលមានផ្ទៃពោះ (N=៨៧២) | | |
| < ១៥ ឆ្នាំ | ១ | ០.១១ |
| >=១៥ ឆ្នាំ <១៨ ឆ្នាំ | ៩៣ | ១០.៦៧ |
| >= ១៨ ឆ្នាំ | ៦៦៤ | ៧៦.១៥ |
| មិនធ្លាប់មានផ្ទៃពោះ | ១១៤ | ១៣.០៧ |

សម្រាប់បុរសវិញ មានត្រឹមតែ០.៣៤% ប៉ុណ្ណោះដែលបានរៀបអាពាហ៍ពិពាហ៍មុនអាយុ១៥ ឆ្នាំ ខណៈដែលសមាមាត្រនៃបុរសចំនួន៤.៥៩% ទៀតបានរៀបអាពាហ៍ពិពាហ៍នៅចន្លោះអាយុ១៥ដល់១៨ ឆ្នាំ។ បុរសប្រហែល ៧៧.៦៤% បានរៀបអាពាហ៍ពិពាហ៍ក្រោយពេលមានអាយុ ១៨ ឆ្នាំ។

ពេលសួរអំពីស្ថានភាពចុះបញ្ជីអាពាហ៍ពិពាហ៍របស់ពួកគេ អ្នកចូលរួមភាគច្រើន (៦៦.៩៧%) បាននិយាយថា ពួកគេមិនទាន់បានបញ្ចប់នីតិវិធីចុះបញ្ជីអាពាហ៍ពិពាហ៍ជាផ្លូវការទេ។ នៅក្នុងការប្រៀបធៀប មានអ្នកឆ្លើយតបចំនួន ៣២.៨% ប៉ុណ្ណោះបានចុះបញ្ជីអាពាហ៍ពិពាហ៍របស់ពួកគេតាមរយៈដំណើរការចុះបញ្ជីជាផ្លូវការ។ អ្នកចូលរួមចំនួន ០.២៣% បានបង្ហាញពីភាពមិនច្បាស់លាស់ ឬកង្វះការយល់ដឹងជុំវិញប្រធានបទនេះ។

អ្នកចូលរួមភាគច្រើនបានរៀបអាពាហ៍ពិពាហ៍ដោយក្តីស្រលាញ់។ យ៉ាងណាមិញ ភាគរយដ៏ច្រើននៃអ្នកឆ្លើយតបចំនួន ៧% បានរាយការណ៍ថា ការរៀបអាពាហ៍ពិពាហ៍របស់ពួកគេត្រូវបានផ្សំផ្គុំដោយចាស់ទុំ។

